វចនានុក្រមខ្មែរបុរាណ

(តាមសិលាចារឹកបុរេអង្គរ សតវត្ស ៦ - ៨)

DICTIONNAIRE DU KHMER ANCIEN

(D'après les inscriptions du Cambodge du VIe. - VIIIe. siècles)

រៀបរៀងដោយ

បណ្ឌិតសាស្ត្រាចារ្យ

ឡុង សៀម

Prof. LONG SEAM

វចនានុក្រមខ្មែរបុរាណ

(តាមសិលាចារឹកបុរេអង្គរ សតវត្សទី ៦ - ៨)

DICTIONNAIRE DU KHMER ANCIEN

(D'après les inscriptions du Cambodge du VIe. - VIIIe. siècles)

រៀបរៀងដោយ

បណ្ឌិតសាស្ត្រាចារ្យ

ឡុង សៀម

Prof. LONG SEAM

រក្សាសិទ្ធិ

ផ្តល់ថវិកាបោះពុម្ពដោយ :

មូលនិធិតូយ៉ូតា នៃប្រទេសជប៉ុន

Fondation TOYOTA du Japon

បោះពុម្ពដោយរោងពុម្ពភ្នំពេញ

Printed by Phnom Penh Printing House

មាតិកា

១. អារម្ភកថា ..... ក

២. ប្រវត្តិរូបសង្ខេបរបស់ បណ្ឌិតសាស្ត្រាចារ្យ ឆ្លុង សៀម ..... ខ

៣. សេចក្តីថ្លែងអំណរគុណ ..... គ

៤. អំពីសិលាចារឹកនៃប្រទេសកម្ពុជា ..... 1A - 7A

៥. Liste des Inscriptions du Cambodge VI-VIII è.s., classés d'après l'ordre numérique ..... 1B - 8B

៦. រូបភាពសិលាចារឹកខ្លះៗនៃប្រទេសកម្ពុជា ..... 1C - 26C

៧. តួស្រៈខ្មែរមុនសម័យអង្គរ 1D

៨. អក្ខរក្រមភាសាខ្មែរបុរាណបុរេអង្គរ 2D

៩. អក្សរសង្ខេប 3D

១០. វចនានុក្រម ខ្មែរបុរាណ ..... 1 - 641

១១. Quelques traits grammaticaux caractéristiques de l'ancien khmer ..... 1E - 11E

១២. Interprétation phonologique de la notation des voyelles
de la langue khmère du VII ème siècle ..... 1F - 16F

១៣. នរនាម និង ឋានន្តរនាមតាមសិលាចារិកកម្ពុជា ..... 1G - 8G

១៤. ឯកសារយោង Bibliographie ..... 1H - 4H

អារម្ភកថា

វចនានុក្រមខ្មែរបុរាណរៀបរៀងតាមឯកសារសិលាចារឹកកម្ពុជា សម័យមុនអង្គរពីសតវត្សទី១ដល់ទី៨ នាសម័យកាលនៃរាជាណាចក្រនគរភ្នំ គឺជាការងារដែលបន្តដំណែលពីឯកសារវចនានុក្រមភាសាខ្មែរបុរាណតាមសិលាចារឹកពីសតវត្សទី៦ ដល់ទី១៤ ដែលអ្នកនិពន្ធបានចាប់ផ្តើមរៀបរៀងតាំងពីឆ្នាំ១៩៧២មក នៅវិជ្ជាស្ថានបូព៌ានៃបណ្ឌិតសភាវិទ្យាសាស្ត្រសហព័ន្ធរុស្សី ។

នៅប្រទេសកម្ពុជា ការងារវចនានុក្រមខ្មែរបុរាណ ក៏នៅតែបន្តដំណើរដោយមានការបន្ថែមវាក្យស័ព្ទជាបន្តបន្ទាប់ តាមសិលាចារឹកដែលរកឃើញនៅពេលបច្ចុប្បន្ន ។

វចនានុក្រមខ្មែរបុរាណសម័យនគរភ្នំ ពីសតវត្សទី៦ គឺជាឯកសារសំណេរដ៏ថ្លៃថ្នូ ពីព្រោះជាសក្ខីភាពបញ្ជាក់នូវដំណាក់កាលដ៏ចាស់ ដែលប្រជាជនខ្មែរ (សរសេរថា ក្ខេរ ក្នុងសិលាចារឹកមេលប់ស្រុកស្ពាយពល) ព្រមទាំងព្រះមហាក្សត្រទាំងឡាយ មានជាអាទិ៍ ព្រះបាទស្រីមារ: ព្រះបាទកវរ្ម៉ន ព្រះបាទឥសានវ្ម៉ន ។ល។ បានឧស្សាហ៍ចេញអាជ្ញាចារឹក អក្សរថ្មទុកជាឧទាហរណ៍ដល់កូនចៅយុវវ័យជំនាន់ក្រោយឱ្យជ្រួតជ្រាបអំពីព្រឹត្តិការណ៍នានានៃប្រវត្តិសាស្ត្រប្រទេសខ្លួន តាំងពីសម័យសតវត្សទី២ នៃគ្រិស្តសករាជ ដោយហេតុថា សិលាចារឹក រ៉ូកាញ្ញ សរសេរជាភាសាសំស្ក្រិតក៏អាចចាត់ទុកជាឯកសារសំណេររបស់ខ្មែរយើងនាសម័យនោះផងដែរ ។

នៅក្នុងកិច្ចការបំពេញការងារខាងនិរុត្តសាស្ត្រដ៏សំខាន់នេះអ្នកនិពន្ធមានបំណងឱ្យស្នាដៃរបស់ខ្លួនមានលក្ខណៈជាវណ្ណកម្មខាងភាសាផង ខាងអក្ខរក្រមវិចិត្រវចនាផង ដោយមានទាំងបញ្ជូលនូវអត្ថបទ សិលាចារឹកជាអក្សរខ្មែរដើមនាសម័យសតវត្សទី៦ដល់ទី៨ ។

មែនពិត យើងមិនអាចឱ្យតម្លៃដល់កិច្ចការខាងវចនានុក្រមខ្មែរបុរាណទាំងឡាយណាដែលមិនមានសំណេរជាអក្សរខ្មែរដើមឡើយ ហើយមានតែសំណេរជាអក្សរឡាតាំង ។

តាំងពីពេលមុនមក នៅសហរដ្ឋអាមេរិក និងនៅប្រទេសបារាំង មានការបោះពុម្ពផ្សាយវចនានុក្រមខ្មែរបុរាណសរសេរឡើងដោយអក្សរឡាតាំងតែប៉ុណ្ណោះ ហើយកង្វះខាតអក្សរខ្មែរដើមបណ្តាលឱ្យយើងស្ថិតនៅអល់ឯក មិនអាចសរសើរដល់កិច្ចការទាំងនោះ ជាវណ្ណកម្មភាសាខ្មែរបានឡើយ ។

ក្នុងកិច្ចការនិពន្ធវចនានុក្រមខ្មែរបុរាណអ្នកនិពន្ធមិនស្ថិតនៅឯកោ ហើយទទួលភាពកក់ក្តៅដោយសារមានសហការ ខាងការរៀបចំ រៀបរៀង និងបកប្រែពីសំណាក់ ព្រឹទ្ធាចារ្យ ម្យ៉ូ.ប៉ុណ្ណ សាស្ត្រាចារ្យ យ៉ៃង វិរបុត្រ ឈុន ផល្លី មាយ បូ៉ា ប្ជង់ ភីរម្យ ដែលធ្វើការនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងនៅវិជ្ជាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជានិងពីសំណាក់លោក ប្រាក់ សុណ្ណារ៉ា ជាបុរាណវិទូមួយរូបនៅក្រសួងវប្ប:ធម៌ ។កញ្ញា ហ៊ូ អមរា ទី គន្ធី កែម សុនីន និង ជា ណារិន ទាំងអស់គ្នាជានិស្សិតមហាវិទ្យាល័យបុរាណវិទ្យានៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្ប: បានបំពេញអក្ខរក្រមវិចិត្រវចនា(travail calligraphique)សិលាចារឹកដើមព្រមទាំងបានធ្វើកំណែពាក្យអក្ខរវិរុទ្ធ ដ៏ផ្ទិតផ្ទង់ ។ អ្នកនិពន្ធសូមជូនពរឱ្យអ្នកទាំងអស់គ្នាក្លាយទៅជាទ័ពាំងស្ពងឫស្សី ដ៏រឹងមាំនៅអនាគត ។

ប្រវត្តិរូបសង្ខេបរបស់ បណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម

បន្ទាប់ពីបានសិក្សាចប់វិទ្យាស្ថានជាតិគរុកោសល្យនិងមហាវិទ្យាល័យអក្សរសាស្ត្រ នៃសាកលវិទ្យាល័យភ្នំពេញ លោក ឡុង សៀម បានត្រូវតែងតាំងដោយរាជរដ្ឋាភិបាល នៅឆ្នាំ១៩៦៥ ឱ្យធ្វើជាសាស្ត្រាចារ្យភាសាខ្មែរនៅវិទ្យាស្ថាន ទំនាក់ទំនងអន្តរជាតិនៃទីក្រុងមូស្គូ នាឆ្នាំ១៩៦៩លោកបានទទួលអាហារូបករណ៍ដើម្បីរៀបចំនិក្ខេបបទថ្នាក់បណ្ឌិតស្តីអំពី "ការសិក្សាស្រាវជ្រាវនៃនិរុត្តិវិទ្យាភាសាខ្មែរទំនើប" ។លោកបានខិតខំស្រាវជ្រាវ រៀបចំហើយបានការពារ និក្ខេបបទខាងលើនេះដោយជោគជ័យនៅវិទ្យាស្ថានបូព៌ាវិទ្យា នៃបណ្ឌិត្យសភាវិទ្យាសាស្ត្រ សហព័ន្ធរុស្សី ។

ចាប់តាំងពីឆ្នាំ១៩៧១ លោកត្រូវបានបណ្ឌិតសភាវិទ្យាសាស្ត្រជ្រើសរើសឱ្យធ្វើការស្រាវជ្រាវភាសាវិទ្យា នៅវិទ្យាស្ថានបូព៌ាសាស្ត្រ ហើយត្រូវបានតែងតាំងជាព្រឹទ្ធសហការីវិទ្យាសាស្ត្រនៃវិទ្យាស្ថានបូព៌ាវិទ្យា។ នៅក្នុងឋានន្តរសក្តិនេះ លោកទទួលបន្ទុកដឹកនាំក្រុមអ្នកសិក្សាស្រាវជ្រាវភាសាខ្មែរ ដែលនៅក្នុងនេះមានភាសាខ្មែរបុរាណតាមសិលាចារឹក ព្រមទាំងភាសាមន-ខ្មែរ នានានៅក្នុងតណ្ឌូចិន។ នៅឆ្នាំ ១៩៧៦ នៅសាកលវិទ្យាល័យប៉ារីសស័ររបាន លោកបានរៀបចំនិក្ខេបបទ ថ្នាក់បណ្ឌិតរដ្ឋស្តីអំពី " ការស្រាវជ្រាវវចនស័ព្ទវិទ្យានៃភាសាខ្មែរតាមសិលាចារឹកកម្ពុជាពីសតវត្សទី៦ ដល់ទី១៤" ក្រោមការដឹកនាំរបស់បណ្ឌិតសាស្ត្រាចារ្យ ហ្សង់ ដែលវ៉ែ ។ បន្ទាប់ពីឆ្នាំ១៩៧៩ លោកបានធ្វើជាអ្នកដឹកនាំនិក្ខេប-បទថ្នាក់បណ្ឌិតនៃកម្មសិក្សាការីទាំងឡាយរបស់ប្រទេសកម្ពុជា លោកបានមកធ្វើទស្សនកិច្ចនៅមាតុភូមិកម្ពុជាច្រើនដងតាំងពីឆ្នាំ១៩៨២ ។ លោកជាសកម្មជនមួយរូបក្នុងការពង្រីកនិងពង្រឹងសហប្រតិបត្តិការរវាងប្រទេសកម្ពុជានិងសហព័ន្ធ-រុស្សី ជាពិសេសនៅក្នុងវិស័យនៃការបញ្ជូននិស្សិតនិងកម្មសិក្សាការីខ្មែររាប់ពាន់នាក់ទៅសិក្សានៅប្រទេសរុស្សី ។ លោកបានរៀបចំ និងបោះពុម្ពផ្សាយវចនានុក្រមទ្វេភាសា ខ្មែរ - រុស្សី . រុស្សី - ខ្មែរ បានបកប្រែ រៀបរៀងស្បៃវភៅ " ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា" បានបោះពុម្ពស្បៃវភៅ និងអត្ថបទមួយចំនួនធំស្តីអំពីអក្សរសិល្ប៍ ប្រវត្តិសាស្ត្រ ភាសា-ខ្មែរនិងមន-ខ្មែរ ជាភាសាខ្មែរ រុស្សី និងបារាំង ។ចាប់តាំងពីឆ្នាំ១៩៩៣មកដល់ឆ្នាំ១៩៩៧(ខែកក្កដា) ក្នុងឋានៈជាអ្នកឯកទេសស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ លោកបានត្រឡប់មកមាតុភូមិវិញហើយបានធ្វើជាទីប្រឹក្សាក្រសួងអប់រំ ដើម្បីបង្កើតនិងដំណើរការវិទ្យាស្ថានភាសាជាតិព្រមទាំងធ្វើជាសាស្ត្រាចារ្យបង្ហាត់បង្រៀនសិលាចារឹកវិទ្យានិងភាសាវិទ្យា នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្ប:ភ្នំពេញ។ នៅពេលជាមួយគ្នាចាប់តាំងពីខែវិច្ឆិកាឆ្នាំ១៩៩៧ដល់ខែធ្នូឆ្នាំ១៩៩៧មក លោកបានត្រូវតែងតាំងជាទីប្រឹក្សាផ្នាល់របស់នាយករដ្ឋមន្ត្រីទីមួយទទួលបន្ទុកផ្នែកវប្បធម៌ និងអក្សរសាស្ត្រ ។ចាប់តាំងពីឆ្នាំ២000 លោកត្រូវបានតែងតាំងជាទីប្រឹក្សាក្រសួងអប់រំ ទទួលបន្ទុកជាប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា លោកស្ថិតនៅជាបណ្ឌិតសាស្ត្រាចារ្យអ៊ុយណេស្កូ ធ្វើសន្ធិសីទអំពីភាសាវិទ្យានិងបុរាណវិទ្យានៅមហាវិទ្យាល័យបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្ប:នៅភ្នំពេញ ។ សព្វថ្ងៃលោកកំពុងស្រាវជ្រាវ សិក្សាសិលាចារឹកខ្មែរនិងដឹកនាំសារណានិស្សិតយ៉ាងសស្រាក់សស្រាំនៅប្រទេសកម្ពុជា ។

អំណរគុណ

ជាបឋម អ្នកនិពន្ធសូមផ្តល់អំណរគុណដ៏ជ្រាលជ្រៅដល់អង្គការមូលនិធិតូយ៉ូតានៃប្រទេសជប៉ុន (Fondation Toyota du Japon) ដែលបានផ្តល់ថវិកាដ៏ថ្លៃថ្លាសំរាប់ការនិពន្ធ រៀបរៀង និងបោះ-ពុម្ពផ្សាយវចនានុក្រមភាសាខ្មែរបុរាណសម័យមុនអង្គរចំនួន១០០០ច្បាប់ ។

កិច្ចការនិពន្ធវចនានុក្រមខ្មែរបុរាណតម្រូវឱ្យមានឯកសារសិលាចារឹកដើមមួយភាគធំជាចាំបាច់ ដែលអ្នកនិពន្ធបានទៅស្រាវជ្រាវថតយកពីបណ្ណាល័យសាលាចុងបូព៌ាបារាំងនៅទីក្រុងប៉ារីស ហើយដែលអ្នកនិពន្ធសូមផ្តល់អំណរគុណជាងគេគឺតាមរយៈលោកសាស្ត្រាចារ្យ ប៊ែណា ហ្ការ៉ាដ្ឋ ។

អស់រយៈពេលម្តងម្កាលមក អ្នកនិពន្ធបានធ្វើការនៅវិជ្ជាស្ថានបូព៌ានៃបណ្ឌិតសភាវិទ្យាសាស្ត្រនៃសហព័ន្ធរុស្សី ដែលនៅទីនោះមានបណ្ឌិតសាស្ត្រាចារ្យ យូរី ហ្គ្រហ្គោនីញ្យេវ និងយូរី ឡូ ចូលរួមធ្វើការ និងផ្តល់បតិស្តីអំពីវិធីសាស្ត្រនៃការនិពន្ធវចនានុក្រមអស់កំឡុងពេលជាច្រើនឆ្នាំ។អ្នកនិពន្ធសូមគោរពដល់វិញ្ញាណខ្ពង់ខ្ពស់នៃមហាបណ្ឌិតទាំងពីរូបនិងសូមសំដែងកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅដល់វិជ្ជាស្ថានបូព៌ាដែលមានសមាជិកបណ្ឌិតសភា ព្រីម៉ាកូវ ជាប្រធាន ។ បានជួយឲ្យបត្តម្ភដល់ខ្ញុំចំពោះការបំពេញកិច្ចការដ៏មានសារសំខាន់ក្នុងការលើកស្ទួយជួងព្រលឹងនៃវប្បធម៌និងអរិយធម៌ជាតិខ្មែរយើង។

នៅប្រទេសកម្ពុជា អង្គការកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDP) អង្គការយូ-ណេស្កូ (UNESCO) មហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទ-ភ្នំពេញ មហាវិទ្យាល័យបុរាណវិទ្យានៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គឺអង្គការនិងស្ថាប័នទាំងអម្បាលនេះហើយដែលបានផ្តល់ការឲ្យបត្តម្ភខាងសំភារៈ កំលាំងជីវភាពរស់នៅកម្រិតសមរម្យ និងលក្ខភាពដ៏ទូលំទូលាយដើម្បីស្រាវជ្រាវសិក្សាសិលាចារឹក និងចងក្រងវចនានុក្រមខ្មែរបុរាណឱ្យបានសំរេចនៅពេលបច្ចុប្បន្ននិងពេលអនាគត គឺចំពោះអង្គការនិងស្ថាប័នដ៏ខ្ពង្គុន្ធ ។ ។ ។

អំពីសិលាចារឹកនៃប្រទេសកម្ពុជា

អំពីសិលាចារឹកនៃប្រទេសកម្ពុជា

តាមចំនួន និងបរិមាណ សិលាចារឹកប្រទេសកម្ពុជា ជាមរតកនៃសិលាចារឹកសំខាន់ និងប្រកបដោយសំបូរភាពជាងគេមួយនៅលើពិភពលោក ប្រសិនបើប្រៀបធៀបសិលាចារឹកកម្ពុជា ទៅនឹងបណ្ណាឯកសារសិលាចារឹកនៃប្រទេសដទៃទៀត។

នៅក្នុងបញ្ជីដ៏ធំមួយ រៀបចំដោយសាស្ត្រាចារ្យ ហ្ស៊ីក សឺដេស (Georges Coedès, Inscriptions du Cambodge. Vol.XVIII. Paris 1966, Pages 73-255) គេប្រទះឃើញមានសិលាចារឹកកម្ពុជាទាំងអស់ ចំនួន ១.០០៥ ។ នៅឆ្នាំ ១៩៧១ លោកសាស្ត្រាចារ្យ ក្លូដ ហ្សាក់ (បន្ទាប់ពីលោក ហ្ស៊ីក សឺដេស) ដែលជាអ្នកស្រាវជ្រាវសិលាចារឹកកម្ពុជាមួយរូបបានចុះផ្សាយក្នុងអត្ថបទរបស់លោកថា គេបានរកឃើញសិលាចារឹក ចំនួន៤៥ទៀត (Claudes Jacques, Supplément au tome VII des Inscriptions. Cambodge BEFEO. t.L VIII. 1971) ហើយនៅឆ្នាំ ១៩៨៨ លោកបានបញ្ជាក់បន្ថែម ក្នុងអត្ថបទថ្មីមួយទៀតថា សិលាចារឹកប្រទេសកម្ពុជា មានចំនួនទាំងអស់ ១១៥0 (Claudes Jacques, in revue "Dossier, Histoire et Archéologie", No. 125, Paris 1988) ។ ជាលើកទីមួយ អ្នកប្រាជ្ញជាតិហូឡង់មួយរូបនាមហេនរិច ខ្មែន(Heinrich Kern) បានបោះពុម្ពផ្សាយអំពីអត្ថបទសិលាចារឹកខ្លះ ស្តីពីកម្ពុជា នៅឆ្នាំ១៨៧៣ ។ បន្ទាប់ពីការបោះពុម្ពផ្សាយសិលាចារឹកកម្ពុជា ដោយអ្នកប្រាជ្ញបារាំងខាងភាសាសំស្ក្រិតនាម អ្ហ្ស្ត ប៉ាថ (Auguste Bath) និងអាបែល ប៊ែរហ្គែញ(Abel Bergaigne) និងដោយលោក អ៊ែម៉ូនីយេ (M. Aymonier) ដោយលោក លុយណេ ដឺឡាហ្សុង គីជេ(Lunet de Lajonquière, Inventaire descriptif des monuments du Cambodge, 3 Vol, Paris 1902-1911) ព្រមទាំង ដោយសារការប្រឹងប្រែងឥត សំចៃកម្លាំងពីសំណាក់សាលាបារាំងចុងបូព៌ា (Ecole Française d'Etrême-Orient) ចំនួនសិលាចារឹក ប្រទេសកម្ពុជា ដែលគេបានរកឃើញ និងបោះពុម្ពផ្សាយ ក៏កាន់តែលូតលាស់ជាអចិន្ត្រៃយ៍ រហូតមកដល់សព្វ ថ្ងៃ ។ នាសម័យបច្ចុប្បន្ន ការងារស្រាវជ្រាវ និងបោះពុម្ពផ្សាយសិលាចារឹកដែលគេបានរកឃើញថ្មីៗ កំពុងប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ប្រទេសបារាំង ប្រទេសថៃឡង់ ។ សម័យកាលនៃបុរាណសិលាចារឹកកម្ពុជា គឺលាតសន្ធឹងតាំងពីសតវត្សទី៦ ដល់ទី១៤ នៃគ.ស. បានសេចក្តីថា ចាប់ផ្តើមតាំងពីសម័យកាលនៃរាជាណាចក្រនគរភ្នំ ឬ ហ្ហ្ជ្ជ (គឺជាឈ្មោះដើមនៃប្រទេសកម្ពុជា) រហូតដល់សម័យកាលខាងចុងនៃចក្រភព "កម្ពុជទេស" (Kambujadeça) ។

សិលាចារឹកចាស់ជាងគេ សរសេរជាភាសាខ្មែរ គឺសិលាចារឹកអង្គរបូរី (K.600) ដែលមានដាក់កាលបរិច្ឆេទឆ្នាំ ៥ពាព មហាសករាជ ត្រូវគ្នានឹងឆ្នាំ ៦១១ គ.ស. ។ ក្រៅពីសិលាចារឹកមួយចំនួននៅអង្គរបូរី ដូចជាសិលាចារឹកវត្តផ្ទែង (ក្ងសាំងស៊ីន) K.1, សិលាចារឹកវត្តពោធិ៍ង្ស្ងលើ (ក្ងសាំងស៊ីន) K.11, សិលាចារឹកអង្គរបូរី K25, សិលាចារឹកព្រះវិហារធំ (កំពង់ចាម) K.520, សិលាចារឹកទួលវត្តគំនូរ (តាកែវ) K. 557, សិលាចារឹកទួលអង្ក (តាកែវ) K.559, ដែលបានបាត់កាលបរិច្ឆេទ មានអក្ខរាវិរុទ្ធចាស់បុរាណជាងសិលាចារឹក K.600 ទៅទៀត ។ គឺនៅលើមូលដ្ឋាននៃអក្ខរាវិរុទ្ធនេះ ហើយ ដែលគេសន្និដ្ឋានបានថា សិលាចារឹកជាភាសាខ្មែរ បានត្រូវចារឡើងនៅសតវត្សទី ៦ ។

តាមគំនូសផែនទីផ្សេងៗ រៀបចំឡើងដោយលោក ហង្សរ ប៉ារម៉ង់ទីយេរ (Henri Parmentier. - Cartes de l'Empire Khmer d'après la situation des inscriptions datées "BEFEO. t. XVI. 3. 1916) ដែលមានឈ្មោះថា "ផែនទីនៃចក្រភពខ្មែរ រៀបចំឡើងតាមទីកន្លែង នៃសិលាចារឹកមានកាល បរិច្ឆេទ" ។ គេអាចឃើញថា ទីកដីគ្របដណ្ដប់ដោយសិលាចារឹកសរសេរជាភាសាខ្មែរ និងសំស្ក្រិតមានទំហំ ធំធេង ។ ទីតដីនេះលាតសន្ធឹងលើប្រទេសកម្ពុជា បច្ចុប្បន្ន លើកូសាំងស៊ីន លើប្រទេសស្យាមប៉ែកបូពិ លើប្រទេសឡាវប៉ែកខាងទក្សិណ គឺជាទីកដីដែលបានមានឯកភាពខាងនយោបាយ និងវប្បធម៌ ។ គ្រាន់តែនៅ សម័យសតវត្សទី ៧ គឺសម័យកាលខាងក្រោយនៃនគរភ្នំ សិលាចារឹកចំនួន ២៣០ បានត្រូវគេរកឃើញនៅ ប្រទេសកម្ពុជា ហើយសិលាចារឹកចំនួន ៥៥ បានត្រូវគេរកឃើញនៅប្រទេសជិតខាងទាំងបី ។ គ្រាន់តែនៅ ប្រទេសស្យាម សិលាចារឹកកម្ពុជា នាសតវត្សទី ៧ បានត្រូវគេរកឃើញនៅទីក្រុង និងខេត្តផ្ទាយ១ ដូចជា ខេត្តពិស្ណុលោក ស៊ីទេព អាយុធ្យា ជាដើម ។ តាមភស្ដុតាងនៃសិលាចារឹកនាសតវត្សទី ៧ ដែលគេបានរកឃើញទាំងនៅ ប្រទេសកម្ពុជា ទាំងនៅប្រទេសដទៃ ដូចជានៅ ខេត្តប្រាជិនបុរីនៅប្រទេសថៃឡង់ (K.506) នៅខេត្តសាដែក ក្នុងដែនកូសាំងស៊ីន (K.9). គេអាចយល់ថា នៅសតវត្សទី ៧ ភាសាខ្មែរ ត្រូវបានប្រើប្រាស់ក្នុងលក្ខណៈនៃភាសាសរសេរនៅលើទីកដីដ៏ធំទូលាយ ដោយអ្នកស្រុកផង ដោយមជ្ឈដ្ឋានរាជការផង ។

សិលាចារឹកទាំងឡាយ គឺជាអត្ថបទមានលក្ខណៈប្រវត្តិកថា (historiographiques) ឧទ្ទិសកថា (commémoratifs) ពណ្ណនាកថា (narratifs) ឬមានលក្ខណៈជា អត្ថបទរដ្ឋការ (administratifs) ជាអត្ថបទ បញ្ជិកា ស្ដីអំពីនរនាម និងស្ថានានាម (répertoires des anthroponymes et toponymes). គឺជាអត្ថបទ ដែលគេចារនៅតាមសរសេរ ស្ដម្ភដាក់នៅចំពីមុខព្រះវិហារ ឬប្រាសាទ លើទ្វារចូល លើជញ្ជាំងផ្ទ លើសិលាស្ដម្ភ ។ គឺជាសិលាចារឹកសរសេរជាភាសាខ្មែរ ឬជាភាសាសំស្ក្រិត ឬមួយសរសេរជាភាសាទាំងពីរតែម្ដង ។ ប៉ុន្តែ ទោះបីដូចនេះក្ដី មិនមែនមានន័យថា ជាសិលាចារឹកទ្វេភាសាទេ ព្រោះថា អត្ថបទជាភាសាសំស្ក្រិត និង ភាសាខ្មែររៀបរាប់អំពីបញ្ហាខុសៗគ្នា ឬក៏បំពេញន័យដែលមានការខ្វះខាតនៅក្នុងអត្ថបទមួយទៀត ។ អក្ខរវិធីដែលគេប្រើប្រាស់សំរាប់សរសេរអត្ថបទសិលាចារឹកជាភាសាខ្មែរ គ្មានលក្ខណៈខុសគ្នាអ្វីពីសិលាចារឹកជា ភាសាសំស្ក្រិតឡើយ ។ គឺជាអក្ខរវិធី មានកំណើតពីប្រព័ន្ធអក្សរព្រហ្មី (brahmi) ដែលមានន័យថា "អក្សរ បង្កើតដោយព្រះព្រហ្ម" ។ មានសិលាចារឹកខ្លះ ជាពិសេស នាសម័យអង្គរ ត្រូវបានគេចារតាមអក្ខរវិធីពីរបែប (digraphiques) គឺអត្ថបទមួយប្រើអក្សរព្រហ្មី តាមបែបខ្មែរ និងអត្ថបទដដែលមួយទៀត ប្រើអក្សរ ទេវនាគរី (devanagari) ។

ជាងមួយសតវត្សមកហើយ សិលាចារឹកកម្ពុជាមួយចំនួនធំ សរសេរជាភាសាសំស្ក្រិត និងជាភាសា ខ្មែរ បានត្រូវបកប្រែជាភាសាបារាំង ហើយបោះពុម្ពផ្សាយដោយលោក ល្វីស ហ្វីណូត៍ (Louis Finot) នៅក្នុងទស្សនាវដ្ដីនានា មានទស្សនាវដ្ដីអាស៊ីយ៉ាទិក (Journal Asiatique) នៅក្នុងព្រឹត្តិបត្រនៃសាលាបារាំងចុង បូពិ (Bulletins de l'Ecole Française d'Extrême-Orient) នៅក្នុងស្បៃវភៅកម្រងអត្ថបទសិលាចារឹកប្រទេសស្យាម (Recueil des Inscriptions du Siam) ។ល។ នៅសម័យបច្ចុប្បន្ន សិលាចារឹកកម្ពុជា ដែលគេមិនបានបោះពុម្ពនៅពេលមុន ឬ ដែលលគេទើបនឹងរក

ឃើញនៅពេលថ្មីៗ បានត្រូវបោះពុម្ពផ្សាយដោយ លោកសាស្ត្រាចារ្យ សាវ៉ារ៉ាស ពៅ ឡុង ស្យ៉ាម ក្លូដ ហ្សាក់ ព្រមទាំងដោយក្រុមអ្នកសិក្សាសិលាចារឹកនៃ ប្រទេសថៃឡង់ ។

ក្រៅពីការបោះពុម្ពផ្សាយ ដូចបានពណ្ណនាខាងលើ សិលាចារឹកកម្ពុជា បានទទួលការបោះពុម្ពផ្សាយដ៏ សំខាន់ៗ នៅក្នុងស្យ៉ាវ៉ាភៅដូចតទៅ :

១. "សិលាចារឹកកម្ពុជា បោះពុម្ពផ្សាយក្រោមការឧបត្ថម្ភរបស់បណ្ឌិត្យសភាសិលាចារឹក និង អក្សរសាស្ត្រ" ប៉ារីស . គ.ស ១៩២៦ ។ ទាំងអស់ គឺមាន ៦ ភាគ ដែលនៅក្នុងនោះ មានផ្ទាំង និង រូបថតសិលាចារឹក ដើមចំនួន២៨៧ ។ គឺជាឯកសារសិលាចារឹកដើមដ៏សំខាន់ ដែលគេអាចធ្វើការសិក្សាប្រវត្តិនៃអក្សរខ្មែរសម័យ អង្គរ និងក្រោយអង្គរ ។ (Inscriptions du Cambodge. publiées sous les auspices de l'Academie des Inscriptions et Belles Lettres. Paris 1926-1937: 6 tomes) ។

២. "សិលាចារឹកកម្ពុជា" បោះពុម្ពដោយសាលាបារាំងចុងបូព៌ា ប៉ារីស ហាណូយ គ.ស ១៩៣៧-១៩៦៦ ។ ទាំងអស់ គឺមានស្យ៉ាវ៉ាភៅ ៨ក្បាល ។ គឺជាកម្រងសិលាចារឹកជាភាសាខ្មែរ និង សំស្ក្រិត សរសេរជា អក្សរឡាតាំង (translittération indianiste) ដែលមានការបកប្រែ និងអត្ថាធិប្បាយជាភាសាបារាំង ដោយលោក ប៊ីរ្ហក ស៊ីដេស ។ នៅក្នុងស្យ៉ាវ៉ាភៅក្បាលទី ៨ មានបទានុក្រមនៃនរនាម ទេវនាម ស្ថាននាម ព្រមទាំងបញ្ជីកាទូទៅនៃសិលាចារឹកកម្ពុជា ។ (G. Coedès. " Inscriptions du Cambodge". publiées par l'Ecole Française d'Extrême-Orient. Paris. Hanoi. 1937-1966) : 8 tomes ។

៣. "សិលាចារឹកកម្ពុជា" កាល់កុត្តា (ឥណ្ឌា) គ.ស ១៩៥៣ ។ គឺជាកម្រងអត្ថបទសិលាចារឹកភាសាសំស្ក្រិត បោះពុម្ពផ្សាយតាមអក្សរទេវនាគរីទំនើប ដោយសាស្ត្រាចារ្យ ម៉ាស៊ុំដារ ។ គ្មានការបកប្រែ ប៉ុន្តែមានអត្ថាធិប្បាយចំពោះសិលាចារឹកសំខាន់ៗ ។ (Majumdar R.C. Inscriptions of Kambuja. Calcutta 1953) ។ សិលាចារឹកទាំងឡាយបោះ-ពុម្ពផ្សាយទាំងបីបែបខាងលើអាចចាត់ទុកបានថាជាប្រភពឯកសារសិលាចារឹកដ៏សំខាន់ម្យ៉ាងសំរាប់ការសិក្សាស្រាវជ្រាវ វប្ប ធម៌ និងអរិយធម៌ខ្មែរបុរាណ ។ ប៉ុន្តែគំនរឯកសារសិលាចារឹកម្យ៉ាងទៀត ដែលជាឯកសារដើម ហើយពុំទាន់ទទួលការបោះពុម្ពផ្សាយ គឺស្ថិតនៅក្នុងបណ្ណាល័យរបស់សាលាបារាំងចុងបូព៌ា និងនៅបណ្ណាល័យជាតិទីក្រុងប៉ារីស នៃប្រទេសបារាំងតែ ប៉ុណ្ណោះ ។ នៅបណ្ណាល័យសាលាបារាំងចុងបូព៌ានៅទីក្រុងប៉ារីស មានអត្ថបទដើម (estampages) នៃសិលាចារឹកកម្ពុជា នាសម័យអង្គរ សម័យក្រោយអង្គរ សឹងគ្រប់សព្វទាំងអស់ ។

អំពីខ្លឹមសារនៃសិលាចារឹកជាភាសាសំស្ក្រិត និងជាភាសាខ្មែរ គឺមានក្នុងអត្ថាធិប្បាយដូចតទៅ ។ សិលាចារឹកជាភាសាសំស្ក្រិត មានចំនួនទាំងអស់៥០ពាន់ អត្ថបទ (តាមការបូកសរុបរបស់លោក ហ្ស៊ីលីប-ហ្សេន្ណែ) ។ ជាសិលាចារឹកសរសេរឡើងជាកំណាព្យ (ការ្យ) ហើយជាទូទៅមានការពណ្ណនាអំពីស្ថាបនកម្មខាងសាសនា (ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា) ជារឿយៗ សិលាចារឹកជាភាសាសំស្ក្រិត ចាប់ផ្តើមប្រារព្ធដោយការបួងសួងដល់ទេវមួយអង្គ ឬច្រើនអង្គនៃព្រហ្មញ្ញសាសនា តាមកំណាព្យ ការ្យឃ្លោងុ ពោរពេញដោយទស្សនៈទេវនិយម និងទស្សនវិជ្ជា ស្រង់ចេញមកពីគម្ពីរវេទ តាមកំណាព្យស្ពតី សរសើរដល់ព្រះមហាក្សត្រសោយរាជ្យ ដោយរៀបរាប់អំពីប្រវត្តិនៃរាជវង្សានុវង្ស អំពីបុព្វកិច្ចនៅ

ក្នុងសមរភូមិប្រឆាំងពួកខ្មាំងសត្រូវពីប្រទេសជិតខាង អំពីការកោតសរសើរដល់ព្រះកិត្តិនាម និងប្រាជ្ញាឈ្លីឆ្លៀវ ដល់សម័យកាលនៃរាជសម្បត្តិ ដែលបានផ្តល់ភាពចំរើនរុងរឿង និងមហិទ្ធិឫទ្ធិ ដល់ព្រះមហានគរកម្ពុជទេស។ មានកំណាព្យខ្លះ ពណ៌នាសរសើរដល់ឥស្សរជនជាន់ខ្ពស់ ជាបព្វជិត ឬជាគ្រហស្ថ ដែលមានសន្ធានចិត្តជ្រះថ្លាចំពោះសាសនា ដោយការកសាងប្រាសាទ វត្តអារាម ស្រុកភូមិ សួនឧទ្យាន បារាយណ៍ និងទំនប់ទឹក។ ភាគច្រើននៃសិលាចារឹកពណ៌នាបញ្ជាក់អំពីនាមស្ថាបនករ ប្រាសាទ ព្រះវិហារ រូបបដិមា ព្រមទាំងកាលបរិច្ឆេទនៃស្ថាបនកម្ម។ កំណាព្យខ្លះទៀត រៀបរាប់ព្រឹត្តិការណ៍តាមបែបប្រវត្តិសាស្ត្រ ស្តីអំពីការប្រយុទ្ធស្ទាប់រស់ រវាងមេទ័ពប្រឆាំងនឹងមេទ័ពមានភក្តីភាពចំពោះរាជានិយម។ មានកំណាព្យប្រកបដោយសោកនាដកម្មដែលនិពន្ធដោយព្រះនាងឥន្ទ្រទេវី ស្តីអំពីពិធីបូងសួងធ្វើភាវនាធម៌ ជារៀងរាល់ថ្ងៃ ពីសំណាក់ព្រះ នាងជយរាជទេវី ដើម្បីជ័យជំនះរបស់ព្រះស្វាមី គឺព្រះបាទជ័យវ៉ន្ទនទី ៧ ដែលធ្វើចម្បាំងប្រឆាំងប្រទេសចម្ប៉ា។ មានអត្ថបទកំណាព្យពីរដ៏វែង មួយគឺសិលាចារឹកបក្សីចាំក្រុង ដែលនិទានអំពីព្រំប្រទល់ កម្ពុជ - ទេស សម័យអង្គរ (ខាងបូពិទល់នឹងប្រទេសចម្ប៉ា ខាងបស្ចឹមទល់នឹងប្រទេសភូមា ខាងឧត្តរទល់ ប្រទេសចិន ខាងទក្សិណទល់នឹងមហាសាគរ) និងសន្ធតិវង្សព្រះបាទវាជេន្ទ្រវ៉ន មួយទៀត គឺសិលាចារឹកវត្តស្រីសន្ធរ ដែលធ្វើ អត្ថាធិប្បាយអំពីទ្រឹស្តីពុទ្ធនិយម និងពិធីសក្ការបូជាក្នុងជំនឿលើពុទ្ធសានាមហាយាន។

នៅក្នុងសៀវភៅស្តីពីការស្រាវជ្រាវវចនសព្ទភាសាសំស្ក្រិត តាមសិលាចារឹកនៃប្រទេសកម្ពុជា លោកភត្តឆារយ បានមានប្រសាសន៍ថា "ភាសាសំស្ក្រិត ប្រើប្រាស់ក្នុងសិលាចារឹកកម្ពុជា មានលក្ខណៈត្រឹមត្រូវល្អ" (K. Bhattacharya, Recherches sur le vocabulaire des inscriptions sanscrites du Cambodge, Paris, 1964) ។

កំណាព្យសំស្ក្រិតតាមសិលាចារឹក បានត្រូវចងក្រងឡើងតាមរចនាបថដ៏ខ្ពង់ខ្ពស់ គប្រ្ចីកគម្ប្រេងពោរពេញដោយពាក្យប្រៀនប្រដៅ សំនួនវោហារ បុគ្គលាធិដ្ឋាន (Paraboles) និងរូបារម្មណ៍ដ៏រស់រវើក តាមរបៀបរៀបចំចង្វាក់ ចាប់ចុងចូន តាមលក្ខណៈរណ្ដំព្យាង្គដ៏ពិរោះ។ កំណាព្យជាភាសាសំស្ក្រិត បានត្រូវសរសេរឡើង ដើម្បីសូត្រដូចជាធម៌ស្ងួត ឬដើម្បីច្រៀងជាបទចំរៀងស្ងួតី កោតសរសើរដល់អាទិទេពនានា (មានព្រះឥសូរ ព្រះពិស្ណុ ព្រះព្រហ្ម) ដល់ព្រះពុទ្ធ ព្រះពោធិសត្ត និងដល់ព្រះមហាក្សត្រ ដោយមានរបាំ ១ របៀបរបាំព្រះរាជទ្រព្យ និងក្រុមតូរ្យតន្ត្រី ប្រគុំកំដរជាប្រក្រតី។ ប្រសិនបើយោងទៅតាមប្រភេទនៃព្រឹត្តិការណ៍ដែលចោទឡើង និងជីវប្រវត្តិ ព្រមទាំងគោរមងារ១ របស់កវី បណ្ឌិត គេអាចសន្និដ្ឋានបានថា កវីបណ្ឌិតទាំងនោះ គឺជាអ្នកប្រាជ្ញខាងភាសាសំស្ក្រិត ដែលមានដើមកំណើតជាជនជាតិកម្ពុជា ហើយមិនមែនជាកវីមកពីប្រទេសឥណ្ឌា ដូចជាពាក្យពោលរបស់លោក ក្លូដ ហ្សាក់ ឡើយ។ កវីបណ្ឌិតទាំងអម្បាលម៉ានទាំងនោះ ១ មែងធ្វើជារាជគ្រូ នៃព្រះមហាក្សត្រ ជាព្រាហ្មណ៍បុរោហិត ជាចតុរាចារ្យ ជាសេនាមាត្យនៅបរមរាជវាំង ហើយដែលបានរៀនសូត្រគម្ពីរវេទ គម្ពីរធម៌សាស្ត្រ និតិសាស្ត្រទាំងឡាយ ខាងព្រាហ្មញ្ញសាសនា ឬ គម្ពីរខាងពុទ្ធសាសនាជាភាសាសំស្ក្រិត។ នេះជាទង្វើការណ៍ដ៏សំខាន់បំផុត ដើម្បីអោយយើងអាចធ្វើការសន្និដ្ឋានបានថា កំណាព្យជាភាសាសំស្ក្រិតតាមសិលាចារឹកកម្ពុជា គឺពិតជាវណ្ណកម្ម ឬ និម្មានកម្មនៃអក្សរសាស្ត្របុរាណ នៃប្រទេសកម្ពុជា ពីសតវត្សទី ៣ (តាមសិលាចារឹកវ៉ូកាញ) ឬទី ៥ ដល់ សតវត្សទី ១៤ នៃគ្រីស្តសករាជ។ ពិតមែនហើយ នាសម័យបច្ចុប្បន្ន គេអាចពិនិត្យឃើញថា ប្រជាជនកម្ពុជា ពុំទាន់ដែល បានក្រេបជញ្ជក់នូវរសជាតិ និងសោភ័ណភាពដ៏ស្រស់បំព្រងនៃអក្សរសាស្ត្របុរាណ

របស់ខ្លួនជាភាសាខ្មែរនៅឡើយដោយ ហេតុថា កំណាព្យសំស្ត្រីតតាមសិលាចារឹកទាំងប៉ុន្មានពុំដែលបានទៅជា កម្មវត្ថុនៃការបកប្រែមកជាកំណាព្យជាភាសាជាតិនៅឡើយ ។

សិលាចារឹកជាភាសាខ្មែរ មានចំនួនទាំងអស់ ៦១៩ អត្ថបទ ហើយនៅក្នុងចំនួននេះមានសិលាចារឹកសម័យមុនអង្គរ (គឺពីសតវត្សទី ៦ ដល់សតវត្សទី ៨) ចំនួន ១៦៤ អត្ថបទ។ សិលាចារឹកសម័យអង្គរ (ពីសតវត្សទី ៩ ដល់សតវត្សទី ១៤) ចំនួន ៤៥៥ អត្ថបទ។

ខុសពីសិលាចារឹកភាសាសំស្ត្រីត សិលាចារឹកជាភាសាខ្មែរទាំងអស់ ត្រូវបានរៀបរៀងឡើងជាពាក្យសម្រាយប្រកបដោយរចនាបថធម្មតាច្បាស់លាស់ គ្មានលក្ខណៈអច្ឆរិយភាព។ គឺជាអត្ថបទប្រកបដោយតថភាព ដែលគេបានចារឡើងសំរាប់សំរួលដល់ការយល់ដឹង នៃបណ្ដាជនភាគច្រើន ដែលគ្មានចំណេះដឹងខាងភាសាសំស្ត្រីត ។ ក្រៅពីអត្ថបទមួយចំនួន ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ អត្ថបទសិលាចារឹកខ្មែរភាគច្រើនអាចចាត់ទុកបានថា ជាឯកសាររដ្ឋការតុលាការ និងពត៌មាន ។ អក្ខរាវិរុទ្ធ និងវចនស័ព្ទប្រើប្រាស់នៅក្នុងសិលាចារឹកជាភាសាខ្មែរ ដែលគេបានរកឃើញនៅលើដែនដីកម្ពុជទេសដ៏ធ្ងាយដាច់ស្រយាលក្ដី ក៏រមែងមានឯកភាពក្នុងការសរសេរប្រកបដោយលក្ខណៈត្រឹមត្រូវ ជាពិសេសអក្ខរាវិរុទ្ធ នៃពាក្យកម្ចីពីភាសាសំស្ត្រីត ឃើញថា អ្នកនិពន្ធសិលាចារឹកខាងភាសាខ្មែរ មានការអប់រំខាងភាសាប្រហាក់ប្រហែលគ្នា ហើយមានចំណេះច្បាស់លាស់ ទាំងខាងភាសាសំស្ត្រីតទៀតផង ។

ការអានអត្ថបទសិលាចារឹកជាភាសាខ្មែរ អាចអោយយើងទទួលចំណេះដឹង និងពត៌មានអំពីទម្រង់ និងរបបគ្រប់គ្រងនៃសង្គមខ្មែរ តាមបញ្ញានានាដូចតទៅ : គឺស្ថាបនកម្ម ប្រាសាទ និងព្រះវិហារ ស្រុក ភូមិស្ថាន នៅលើដែនដីថ្មីៗ សកម្មភាពខាងសាសនា និងខាងសង្គមកិច្ច ពីសំណាក់វណ្ណៈអភិជន និងព្រាហ្មណាចារ្យ ព្រះសង្ឆគ្រប់ជាន់ថ្នាក់ក្នុងកិច្ចការអភិវឌ្ឍន៍ស្រុកទេស និងក្នុងកិច្ចការរដ្ឋបាល អំណោយទានដ៏ធំធេង មានតាំងពីដីធ្លី ច្បារដំណាំ ស្រែ ចំការ ទាសាទាសី សត្វពាហនៈ គ្រឿងបូជាធ្វើពីមាសប្រាក់ ដល់វត្តអារាម និងអាទិទេព នៃពិធីសក្ការបូជាទេវរាជ ព្រះរាជអាជ្ញា និងព្រះសាសនៈជាលាយលក្ខណ៍អក្សរផ្ទៃតាមព្រះរាជត្រូ ឬព្រាហ្មណាចារ្យ ដល់ប្រធានតុលាការ ដល់ខ្ពោញ្ញពលខេត្ត (វិស័យ) ឬ ដល់បុរសប្រធាន និងប្រធានស្រុកនានា ដើម្បីការអនុវត្តកិច្ចការរាជការគ្រប់បែបយ៉ាង មានជាពិសេស ការ កាប់គាស់ដីថ្មី ដើម្បីចាត់ស្រុក សាងវត្ត ជីកស្រះ ត្រពាំង សង់ទំនប់ទឹក សំរាប់ជាទីតាំងលំនៅនៃបណ្ដាជន គ្រប់ជាន់ថ្នាក់ ចាប់តាំងពី អភិជន ដល់សាមញ្ញជន និងពលកុំ ដែលបំពេញងារតាមចំណាប់ពេលវេលាខាងរនោច ឬខាងខ្នើត ។ តាមសិលាចារឹក គេអាចដឹងថា ការប្រព្រឹត្តទៅនៃទំនាក់ទំនងខាងពាណិជ្ជកម្ម មិនមែនដោយសារតែការប្រើមាសប្រាក់ប៉ុណ្ណោះទេ តែដោយសារការប្រើគ្រឿងវត្ថុ ផលដំណាំ គ្រប់ជំពូក (មានកប្បាស ស្រូវ) ព្រមទាំងសត្វពាហនៈ ដីធ្លី និងទាសាទាសីទៀតផង ។

លក្ខណៈពិសេសនៃអត្ថបទជាភាសាខ្មែរ ដែលគេអាចប្រទះឃើញនៅសឹងគ្រប់សិលាចារឹកសម័យអង្គរ និងមុនអង្គរ គឺការពណ៌នាអំពីការកំណត់ព្រំប្រទល់ស្រុក ភូមិស្ថាន និងស្រែចំការរបស់វត្តអារាម និងរបស់វណ្ណៈអភិជន ដែលបានមកពីព្រះរាជអំណោយ និងអំពីនរនាម (គឺនាមឈ្មោះមនុស្ស) ដែលបំពេញសេវាកម្មគ្រប់បែបយ៉ាងនៅក្នុងប្រាសាទ ឬវត្តអារាមនីមួយៗ ។ ហេតុនេះហើយបានជា តាមសិលាចារឹកជាភាសាខ្មែរ យើងអាចស្រង់បាន នរនាម (anthropo-

nymes) ចំនួនច្រើនជាង ៥.000 ហើយស្ថានានាម (toponymes) ចំនួនប្រហែលជា ១.៥00 ។ តាមសិលាចារឹកកម្ពុជា គេអាចឃើញថា ប្រាសាទ ឬវត្តអារាម គឺជាមជ្ឈមណ្ឌលខាងសេដ្ឋកិច្ច និងវប្បធម៌ និងជាទីពំនឹងដ៏ធំនៃប្រជាជន ។ ទីណា មានវត្តអារាម គឺទីនោះមានស្រុក និងភូមិឋាន មានស្រូវអង្ករ ។ ជាឧទាហរណ៍ តាមសិលាចារឹកវត្តអង្គរបូរី K.600 នាឆ្នាំ ៦១១ មានពណ៌នាអំពីឈ្មោះនៃស្រែចំការ ច្បារដំណាំ បឹងបួរ ដែលជាកសិដ្ឋានផលិតគ្រឿងបរិភោគរបស់វត្ត មានការ ពណ៌នា អំពីនាមឈ្មោះរបស់បំនួស ឬអាចារ្យ មានឈ្មោះអ្នកប្រគុំតូរ្យតន្ត្រី នាដការី របាំ សិល្ប:ការិនី ចំរៀង កសិករ អ្នក ញ្ញាញ្ញ រវៃ ។ល ។

មានអត្ថបទសិលាចារឹកមួយចំនួន ដែលគេចាត់ទុកថា ជាអត្ថបទប្រកបដោយលក្ខណ:ប្រវត្តិសាស្ត្រ ឧទាហរណ៍ សិលាចារឹកស្តុកកក់ធំ K.235 ឆ្នាំ ១0៥២ អធិប្បាយដ៏ល្អិតល្អន់អំពីសន្ធតិវង្សនៃវង្សត្រកូលមួយដែលសមាជិកបំពេញ មុខងារជាព្រាហ្មណ៍បុរោហិត នៃពិធីសក្ការបូជាទេវរាជាសំរាប់ព្រះមហាក្សត្រសម័យអង្គរជាច្រើនអង្គអស់រយ:ពេលពីរ រយឆ្នាំ ។ សិលាចារឹកវត្តសំរោង (ព្រៃវែង) K.956 ដែលរៀបរាប់អំពីកល្យាណវិធីលើមហេន្ទ្របពិត (ភ្នំគូលែន) ដើម្បីអភិសេកព្រះបាទជ័យវ៉ន្ទទី ២ (៨0២-៨៥0 A.D) ជាមហាក្សត្រ ចក្រវ៉ាទ (empereur) នៃកម្ពុជទេស ឯករាជ្យ ។ សិលាចារឹកភិមានអាកាស (ស្យើមរាប) K.292 សរសេរអំពីវិធីធ្វើសម្បថសម្តែងស្វាមីភក្ដិដល់ព្រះបាទស្រី សូរ្យវ៉ន ទី ១ ដោយពាក្យ សន្យាមិនរត់ចោលព្រះចំបាំងប្រឆាំងសត្រូវពីសំណាក់នៃតម្រួតកងទ័ពប្រមាណជាង២00 នាក់ ។ សិលា ចារឹកកំពង់ធំ K.444 បញ្ជាក់អំពីរាជក្រឹត្យ បង្កើតក្រុមមន្ត្រីជាន់ខ្ពស់ថ្មី១របស់ព្រះមហាក្សត្រ ។

តាមអត្ថាធិប្បាយអំពីខ្លឹមសារជាគោល ដែលដក់នៅក្នុងអត្ថបទសិលាចារឹកទាំងឡាយ យើងមានគោលបំណង ដើម្បីបញ្ជាក់ថា តាមទស្សនៈទូទៅ លក្ខណ:អក្សរសិល្ប៍ នៃសិលាចារឹកខ្មែរសម័យមុនអង្គរ និងអង្គរបានលេចឡើង សន្ធោសន្ធៅច្បាស់លាស់ លើមូលដ្ឋាននៃរូបភាពជាក់ស្តែងប្រកបដោយសច្ចភាពនៃជីវិតដ៏រស់រវើក ដ៏តឹងតែង និងពោ-ពេញដោយ ជំនឿដ៏ខ្ជាប់ខ្ជួនលើសាសនារបស់ប្រជាជនកម្ពុជា នាសម័យទាំងពីរ ។

ការសិក្សាសិលាចារឹកកម្ពុជាបោះពុម្ពផ្សាយតាំងពីដើមសតវត្សទី២0 ជាពិសេសដោយលោក ល្វីហ្ជីណូត៍ លោក ប៉ារ្ក សីដេស និងលោកអ្នកប្រាជ្ញដទៃទៀត បានធ្វើអោយយើងយល់ថា ការស្រាវជ្រាវរកសិលាចារឹកកម្ពុជាបានទាមទារ អោយមានកិច្ចការរៀបចំការងារស្រាវជ្រាវតាមក្រុម តាមដំណាក់កាល ដែលស្ថិតនៅក្នុងបរិយាកាសប្រកបដោយក្ដី - ព្យាយាម និងអង់អាចទៀតផង ដោយហេតុថា សិលាចារឹកភាគច្រើន បានត្រូវរកឃើញនៅក្នុងប្រាសាទ នៅក្នុង ព្រៃ នៅក្នុងទីដ៏ឆ្ងាយជាច់ស្រយាលដូចជា ប្រាសាទបន្ទាយឆ្ងារ ព្រះវិហារ កោះកេ្ដ ព្រះខាន់ (កំពង់ធំ) សំបូរព្រៃគុក ។ល ។

សិលាចារឹកទាំងអស់ បានត្រូវគេផ្ដិតយកនឹងក្រដាសក្រាស់ ធ្វើជាអេស្តំប៉ាស (estampages) រួចតម្រូវអោយ មានការសិក្សាតាមការអាន តមកត្រូវបានសរសេរជាអក្សរឡាតាំង (translittération indianiste) រួចបកប្រែ និង ពន្យល់ត្រប់ប្រែបយ៉ាង ហើយបោះពុម្ពផ្សាយជាភាសាបារាំង ។ នៅលើមូលដ្ឋាននៃសិលាចារឹកបោះពុម្ពផ្សាយ អ្នកស្រាវ ជ្រាវនៃប្រទេសនានា (មានប្រទេសបារាំងជាអាទិ៍) បានចងក្រងស្យើវភៅមួយចំនួនធំ ស្ដីពីប្រវត្តិសាស្ត្រខាងនយោ បាយ ខាងសេដ្ឋកិច្ច ខាងសង្គមកិច្ចនៃប្រទេសកម្ពុជា នាសម័យបុរាណ ។ គឺដោយសារសិលាចារឹក គេអាចរៀបចំកាល ប្រវត្តិ (Chronologie) នៃរាជសម្ព្ធិ មហាក្សត្រសម័យអង្គរ និងមុនអង្គរ ស្គាល់ច្បាស់អំពីកាលបរិច្ឆេទនៃស្ថាបនកម្ម

និងអត្ថន័យនៃប្រាសាទធំៗ ស្គាល់នូវជំនឿផ្សេងៗ ប្រកាន់ដោយប្រជាជនចំពោះទេវៈ និងអាទិទេពទាំងឡាយ នៃព្រហ្ម-ញ្ញសាសនា និងពុទ្ធសានាយល់នូវស្រទាប់ និងការលូតលាស់នៃសង្គមខ្មែរ ព្រមទាំងរបបគ្រប់គ្រង ដែលយោងទៅតាម ពិធីសក្ការបូជាទេវរាជ ។

ទោះបីមានការបោះពុម្ពស្ទាដ្ឋៃខាងប្រវត្តិសាស្ត្រ មានច្រើនក្តីក៏ពតិមានខាងវិទ្យាសាស្ត្រ ដែលមានដក់នៅក្នុងសិលាចារឹកនៅមិនរីងស្ងួត ។ សិលាចារឹក គឺជានិម្មាបនកម្មខាងអក្សរសាស្ត្រ ដែលអាចអោយយើងយល់ទម្រង់ និងស្ថានភាពនៃភាសាខ្មែរបុរាណ ។ ការសិក្សាសិលាចារឹកជាភាសាខ្មែរ ក៏មិនមែនជាកិច្ចការងាយស្រួលសិក្សាជាងភាសាសំស្ក្រិតប៉ុន្ថានដែរ ដោយហេតុថា ភាសាសំស្ក្រិត ជាភាសាក្លាស្ស៊ីកបុរាណ ដែលត្រូវបានអ្នកប្រាជ្ញបរទេសជាច្រើន ចងក្រងជាវចនានុក្រមច្រើនបែបយ៉ាង ចំណែកឯកសារខ្មែរបុរាណ គឺជាភាសាអមត: មានអំបូរពីភាសាមន-ខ្មែរ ហើយមានការវិវត្តមកជាភាសាខ្មែរនៃមធ្យមសម័យ និងបច្ចុប្បន្នសម័យដោយមានការប្រែប្រួលខាងអក្ខរាវិរុទ្ធ វចនស័ព្ទ និងវេយ្យាករណ៍ ។

នៅពេលដំបូង ការសិក្សាភាសាខ្មែរតាមសិលាចារឹក ពុំទាន់មានចលនាទៅមុខល្បឿន ដូចជា ការសិក្សាប្រវត្តិវិទ្យា និងស្ថាបត្យកម្ម ក៏ប៉ុន្តែ បន្ទាប់ពីពេលបោះពុម្ពផ្សាយសៀវភៅ "សិលាចារឹកកម្ពុជា " ៨ ក្បាលរបស់លោក ប៊ីរ្ហក ស៊ីដេស មក (១៩៣៧-១៩៦៦) ឃើញថា សន្ទុះនៃការសិក្សាស្រាវជ្រាវភាសាខ្មែរតាមសិលាចារឹក បានបោះជំហានទៅមុខយ៉ាងល្បឿន ដោយសារការបោះពុម្ពផ្សាយអត្ថបទសៀវភៅ និងវចនានុក្រម ។ ការសិក្សាភាសាខ្មែរតាមសិលាចារឹក បានប្រព្រឹត្តទៅនៅប្រទេសកម្ពុជា នៅប្រទេសបារាំង នៅប្រទេសអង់គ្លេស នៅសហរដ្ឋអាមេរិក នៅសហព័ន្ធរូស្ស៊ី នៅប្រទេសជប៉ុន នៅប្រទេសថៃឡង់ នៅប្រទេសឥណ្ឌា ។ល ។

នៅពេលបច្ចុប្បន្ន សិលាចារឹកខ្មែរ និងសំស្ក្រិត ត្រូវបានរកឃើញជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ ហើយបូកសរុបគឺមានសិលាចារឹកទាំងអស់ប្រហែល ១៣៥០អត្ថបទ ។ នេះគឺជាមរតកខាងឯកសារអក្សរសាស្ត្រដ៏ធំធេងសំរាប់ប្រទេសកម្ពុជា ។

វចនស័ព្ទនៃភាសាមនបុរាណ បានត្រូវចងក្រងឡើងជាវចនានុក្រមដោយលោក ស័រតូ (H.L. Shorto) និងលោក ហ្ស៊ីរ៉ា ឌីប្ល (G. Diffloth) ។ វចនស័ព្ទវិទ្យាជាភាសាខ្មែរ នៃសិលាចារឹកខ្មែរបុរាណបានត្រូវចងក្រងជា វចនានុក្រមមានជាពិសេស ដោយអ្នកនិពន្ធ ឡុង ស្យៀម ក្រោមចំណងជើងថា " វចនានុក្រមភាសាខ្មែរបុរាណ " ពីសតវត្ស ទី ៦ ដល់ទី១៤ ។ គឺជាវចនានុក្រមដែលមាន ២៤៥០ទំព័រ (អង្គុលីលេខ) រៀបរៀងដោយកិច្ចឧបត្ថម្ភរបស់វិជ្ជាស្ថានបូពិសាស្ត្រ នៃបណ្ឌិត្យសភាសហព័ន្ធរូស្ស៊ី ។ វចនានុក្រមនោះមានមេពាក្យចំនួនជាងមួយម៉ឺន ។ មេពាក្យនីមួយៗ បានត្រូវបកប្រែជាភាសាបារាំង និងរូស្ស៊ី ហើយមានសេចក្តីពន្យល់ដោយឧទាហរណ៍នានា ស្រង់ចេញពីអត្ថបទសិលាចារឹកដោយមានចំណាត់ថ្នាក់តាម កាលបរិច្ឆេទចាប់តាំងពីសតវត្សទី៦ រហូតដល់ចុងសតវត្សទី១៤ ។
វចនានុក្រមបានត្រូវរៀបចំឡើង ដើម្បីឱ្យទៅជាគ្រឿងឧបករណ៍វិទ្យាសាស្ត្រ សំរាប់អ្នកស្រាវជ្រាវ និងនិស្សិតដែលសិក្សាវប្បធម៌ និងអរិយធម៌នៃប្រទេសកម្ពុជា ។

Liste des Inscriptions du Cambodge VI -VIII è.s., classés d'après l'ordre numérique.

Numéro	Province	Lieu d'origine	Situation actuelle	Epoque en ère çaka	Epoque en ère chrétienne A.D.	Bibliographie
k.1	Chaudoc (anc.cochin-chine)	Vat Thlèṅ	In situ	VI-VII	VII-VIII	C, VI, 28
k.6	Sadec (anc.cochin-chine)	Pràsàt Prāṃ Lovêṅ (à Thap Muòi)	Disparue	VI	VII	BE, 36, 5
k.7	Idem	Idem	Idem	VI	VII	BE, 36, 4
k.8	Idem	Idem	Phnoṃ Péñ : 772 (D 3, 15)	VI-VII	VII-VIII	C, II, 79
k.9	Idem	Phu-huu (Pagode de Cái taù hạ)	Saigon : kp 1,1	561	693	C, V, 36
k.11	Tà Kèv	Idem (Vat Pôthivoṅ Lo)	Vàt Utompor kròm	VI-VII	VII-VIII	C, II, 7-8
k.18	Idem	Prei Mîen	Phnoṃ Péñ : 1691; D 3, 27	648	726	C, II, 149
k.21	Idem	Poñā Hòr	In situ	VI	VII	C, V, 5-6
k.22	Idem	Vàt Pô	Musée Guimet: 17.823 (175).			C, III, 144-5 IC, V, 202
k.24	Idem	Aṅkor Bórèi	Phnoṃ Péñ : 4.224 (D 3, 58)	VI	VII	C, II, 16-7 IC, I, 8-9
k.25/555	Idem	Idem	Idem : 4.115 (D 3, 57)	V-VI	VI-VII	C, II, 18 C, VI, 31 IC, I, 10
k.28	Ta Kèv	Phkaṃ	In situ	VI	VII	C, II, 24 IC, I, 15
k.30	Idem	Caṃnòm	In situ	VI	VII	C, II, 27 IC, I, 17
k.37	Idem	Idem (Sanctù-aire Sud)	Idem	VI	VII	C, II, 35 IC, I, 20
k.38	Idem	Vat Tnót	Idem	VI	VII	C, II, 45-6 IC, I, 24
k.41	Idem	Vāt Prei Svā	Disparue	VI	VII	C, VI, 32

k.44	Kāmpot	Praḥ Kūhā Lûoṅ ou Kuhā Kbāl Botum.	In Situ	596	674	C, II, 10 IC, I, 4
k.46	Idem	Phnoṃ Ṅôk		VI	VII	C, VI, 35
k.48	Prei Vêṅ	Vāt Prei Crat	In Situ	VI	VII	C, VI, 27
k.49	Idem	Vāt Prei Vāl		586	664	C, VI, 6
k.51	Idem	Vāt Kdēi Trāp	In Situ	VI	VII	C, V, 14-5
k.54	Idem	Kdei Aṅ	Musée Guimet : 17.827(17-2)	551	629	C, II, 157 IC, V, 206
k.66	Idem	Snày Pol	Phnoṃ Péñ : 6.183; D1, 42	VI	VII	C, II, 52-3 IC, I, 27
k.73/718	Kandàl	Vat Práḥ That	Idem : 3.285 (D 3, 37)	VI	VII	C, VI, 37 C, VI, 52
k.74	Kōmpoṅ Spu	Vat Praḥ Nirpan		619	697	C, VI, 18
k.76	Idem	Phnoṃ Ho Phnou	In Situ	VI	VII	C, V, 8
k.78	Idem	Phnoṃ Bàset	Phnoṃ Peñ (Vat Botūm-vodei)	59x	668-677	C, VI, 12
k.79	Kandāl	Phnoṃ Péñ (provenant de Tā Kèv?)	Phnoṃ Péñ : 6.182; D1, 41	561	639	C, II, 69 IC, I, 33
k.80	Idem	Vat Prei Vêṅ		VI	VII	C, VI, 4
k.90	Kompoṅ Cām	Kuk Praḥ Kôt	In Situ	VI	VII	C, V, 26
k.98	Idem	Bantāy Prei Nokor		VI	VII	C, VII, 32
k.103 S k.103 N	Idem	Praḥ That Praḥ Srēi (Edicule L)	Idem	(ant. à 692) 692	770 770	C, V, 33
k.107	Idem	Praḥ Thāt Khnai Van		VI	VII	C, VI, 38
k.108	Idem	Idem		VI-VII	VII-VIII	C, VII, 38
k.109 N	Idem	Prāsāt Praḥ Thāt	In Situ	577	655	BE, 11, 393 C, V, 41
k.113/114	Idem	Rosei Srok ou Svāy Sat		620(?)	698(?)	C, VI, 20

		Phnom				
k.115	Idem	Sophās	In Situ	587	665	C, VI, 10
k.124	Kracèḥ	Vat Tasar Moroy	Musée Guimet : 17.822 (17-6)	725	803	C, III, 170 IC, V, 209
k.126	Kracèḥ	Saṃbor (Tûol Kôk Prāsāt)		VI-VII	VII-VIII	C, VII, 33
k.127	Idem	Idem (Trapāṅ Prei)	Phnoṃ Péñ : 771 (D 3, 14)	605	683	C, II, 89 IC, II, 47
k.129	Idem	Idem (Tā Kiṅ)	Idem : 719 (D 3, 6)	VI-VII	VII-VIII	C, II, 83-4 IC, II, 44
k.133	Idem	Idem (Trapāṅ Thma)	In Situ	VII	VIII	C, V, 81
k.134	Idem	Lobòk Srót	Phnoṃ Péñ : 711 (D 3, 1)	703	781	BE, 5, 419 C, II, 92 IC, II, 48
k.135	Idem	Idem	Idem : 718 (D 3, 5)	VI	VII	C, II, 95 IC, II, 49
k.137	Koṃpoṅ Chnāṅ	Loṅvêk (?)	Idem : 732 (D 3, 10)	VI	VII	C, II, 116-7 IC, II, 55
k.138	Idem	Pràtsàt Tóc	In Situ	542	620	C, V, 18
k.140	Koṃpoṅ Thoṃ	Vat Bārāy	Idem	598	676	C, VI, 14
k.145	Idem	Pràsàt Phum Pràsàt ou Pràsàt Sralau	Idem	628	706	C, VI, 72
k.146	Idem	Kakòḥ	Vat Cha	VI-VII	VII-VIII	C, VI, 80
k.149	Idem	Saṃbor Prei Kūk (édifice N18)	In Situ	VI	VII	C, IV, 28-9
k.154	Kandāl	Phum Koṃrîeṅ	Phoṃ Péñ : 715 (D 3, 3)	606	684	C, II, 123 IC, II, 58
k.155	Koṃpoṅ Thoṃ	Kôk Rokā	In Situ	VI-VII	VII-VIII	C, V, 64
k.159	Idem	Pràsàt Beṅ	Idem	VI-VII	VII-VIII	C, VI, 40
k.163	Idem	Ampil Rolūm (Tour Nord)	Idem	VI-VII	VII-VIII	C, VI, 100-1
k.259	Siem Rāp	Vat Khnāt	Détruite	VII	VIII	C, VII, 53
k.341	Koṃpoṅ	Prāsāt Nāk	In Situ	622 (?)	700 (?)	C, VI, 23

S..	Thoṃ	Buos (Sanctu-aire L)				
k.341 N...	Idem	Idem	Idem	596 (?)	673 (?)	C, VI, 23
k.357	Idem	Prāsāt Koṃpoṅ	Idem	VI	VII	C, VI, 41-2
k.388	Nākōn Rācāsīma (Siam)	Hin Kôn	Idem	VI	VII	C, VI, 75-6
k.389	Idem	Idem	Idem	VI	VII	C, VI, 78-9
k.416	Koṃpoṅ Spu	Residence	Phnoṃ Péñ : 6.185; D1, 44	VI	VII	C, II, 47 IC, I, 25
k.422	Tā Kèv	Cān Cūṃ	Vāt Pôthivoṅ Lo	VI	VII	C, II, 9 IC, I, 2
k.423	Koṃpot	Trapāṅ Thoṃ	Phnoṃ Péñ : 714 (D 3, 2)	VI	VII	C, II, 135 IC, II, 63
k.424	Koṃpoṅ Spu	Phnoṃ Mraḥ Prou	Idem 6.181 (D 1, 40)	VI	VII	C, II, 73-4 IC, I, 34-35
k.426	Kandāl	Coṅ Ek	Idem 728 (D 1, 5)	VI	VII	C, II, 121 IC, II, 57
k.427	Koṃpoṇ Spu	Tûol Praḥ Thāt	Phnoṃ Péñ : 3.460; D3, 46	VI	VII	C, VI, 43
k.430	Kracéḥ	Phnoṃ Saṃbok ou Phnoṃ Pros	In Situ	VI	VII	C, VI, 44
k.438	Koṃpoṅ Thoṃ	Saṃbor Prei Kūk (Edifice N16)	Phnoṃ Péñ : 734 (D 1, 1)	VI	VII	C, IV, 27
k.447	Bāttaṃbaṅ	Bāsēt	Idem : 1.830 (D 3, 28)	57 x	648-657	C, II, 193 IC, II, 88
k.451	Siem Rāp	Prāsāt Prei Thnāl (sud)	Disparue	602	680	C, V, 49
k.480	(Cambodge)		Phnoṃ Péñ : 773 (D 3, 16)	VI	VII	C, II, 191-2 IC, II, 87
k.482	Koṃpoṅ Thoṃ	Kôk Rokā	In Situ	VI	VII	C, V, 29
k.493	Prei Vêṅ	Tûl Kôk Prāḥ	Phnoṃ Péñ : 819	579	657	BE, 17, (10)

			(D 3, 17)			C, II, 149 IC, II, 71
k.502	Pracinbūri (Siam)	Vat Sābāp (inscr. mutilée) et Vat T'ung Thuā (fragm.)	Bangkok (Musée)	VI	VII	BE, 24, 355
k.505	Idem	Khāu Rāng	Idem	561	639	C, V, 23
k.557	Tā Kèv	Tûol Vāt Komṇu	In Situ	533	611	C, 11, 21 IC, I, 13
k.559	Tā Kèv	Tûol Aṅ	Vat Khnāt Trapōk	VI	VII	C, II, 36 IC, I, 21
k.560/739	Idem	Vāt Aṅ Khvāv	Phnoṃ Péñ : 3318 (D 3, 42)	VI-VII	VII-VIII	C, II, 37 C, VI, 54 IC, I, 22
k.561	Idem	Tûol Aṅ Tnōt	Vat Aṅ Tnòt	603	681	C, II, 39 IC, II, 47
k.562	Idem	Tûol Aṅ Khvāv	Phnoṃ Péñ : 1.831; D3, 29	VI	VII	C, II, 196-7 IC, II, 89
k.563	Komṇoṅ Spu	Phum Crei	Idem : 1.832 (D 1, 14)	VI	VII	C, II, 198 IC, II, 90
k.582	Idem	Trai Trak (Tûol Tramuṅ)	Idem : 2.039 (D 3, 31)	615	693	C, II, 200 IC, II, 91
k.590	Battaṃbaṅ	Tûol Komṇāp	In Situ	VII	VIII	C, III, 130-1 IC, III, 140
k.600	Tā Kèv	Aṅkor Borei	Phnoṃ Péñ : 4.221; D 4, 9	533	611	C, II, 21
k.648	Komṇoṅ Cām	Nāk Tā Tāṅ Tāy	In Situ	VI	VII	C, VI, 16
k.657	Komṇoṅ Thoṃ	Phnoṃ Praḥ Lān	Idem	VI	VII	C, VI, 46
k.664	Kandāl	Saṃbuor	Phnom Péñ : 2.912 (D 1, 16)	VI-VII	VII-VIII	C, V, 69
k.670	Tā Kèv	Phnoṃ Dā	Phnoṃ Péñ : 3379; D 3, 45	VI	VII	C, VII, 88

k.688	Siem Rāp	Prāsāt Prei Prāsāt (sanctuaire N)	In Situ	641	719	C, IV, 36
k.689	Tā Kèv	Vat Pô Rôṅ	Phnoṃ Péñ : 3.073;D 1, 19	VI-VII	VII-VIII	C, VI, 47
k.709	Idem	Trau Tasar	Idem 3.272 (D 1, 23)	VI	VII	C, V, 30-1
k.710	Idem	Tā Lo	Idem : 3.280 (D 3, 35)	VI	VII	C, VI, 49
k.711	Koṃpoṅ Spu	Bel	Idem : 3.283 (D 3, 36)	VI	VII	C, VI, 50
k.712	Idem	Idem	Idem : 3.284 (D 1, 24)	VI-VII	VII-VIII	C, VI, 50
k.719	Tā Kèv	Popél	Idem : 3.286 (D 3, 38)	VI	VII	C, VI, 53
k.723	Basāk	Thām Lekh	In Situ	VI-VII	VII-VIII	C, VI, 12
k.724	Idem	Ide	Idem	VI-VII	VII-VIII	C, V, 12
k.726	Koṃpoṅ' Cām	Tāṅ Kraṅ	In Situ	VII	VIII	C,V, 76-7
k.728			Phnoṃ Péñ : 2.964; D 1, 1	VII	VIII	C, V, 83
k.748	Kandāl	Vat Vihār Trāñ	In Situ	535	613	C, V, 17
k.749	Siem Rāp	Prāsāt Ak Yōṃ (Sanctuaire central, port E.)	Idem	639	717	C, V, 57
k.753	Siem Rāp ...	Prāsāt Ak Yōṃ (Sanctuaire Central, porte S.)	In Situ	626	704	C, V, 58
k.755	Tā Kèv	Vat Chnaḥ	Phnoṃ Péñ : 3.334; B 10, 19	VI	VII	C, VI, 55
k.757	Koṃpoṅ Thoṃ	Vat Bānak	In Situ	VI-VII	VII-VIII	C, VII, 101

k.759	Kandāl	Vat Aṅ Bēṅ Cak	Idem	VI	VII	C, VI, 56
k.764	Komṇoṅ Spu	Vat Aṅ Pisēi (ou V. Prāḥ Srēi)	Idem	VI-VII	VII-VIII	C, VI, 57
k.765	Tā Kèv	Prāsāt Nāṅ Khmau	Idem	60 X	678-687	C, V, 53
k.766	Komṇoṅ Chnāṅ	Vat Tralèṅ Kèṅ	Idem	VI-VII	VII-VIII	C, VI, 58
k.784	Komṇoṅ Spu	Prāsāt Aṅ Praḥ Thnāt	Phnoṃ Péñ : 3.378; D1, 28	VII	VIII	C, VI, 59
k.785	Idem	Id.	Id : 3.37 (D 3, 44)	VI-VII	VII-VIII	C, VI, 59
k.786	Komṇoṅ Chnāṅ	Tûol Vāt Cās	In Situ	VI-VII	VII-VIII	C, VII, 107
k.787	Kandāl	Vat Aṅ Praḥ Pāy	Idem	VI-VII	VII-VIII	C, VI, 60
k.788	Komṇoṅ Spu	Vāt Aṅ Sērēi	Idem	VI-VII	VII-VIII	C, VI, 61
k.790			Phnoṃ Péñ : 3.629; D1, 37	VI	VII	C, V, 71
k.808	Siem Rāp	Prāsāt Olōk	Siem Rāp : 3.101	VI-VII	VII-VIII	C, IV, 37
k.810	Kandāl	Tûol Môṅ	In Situ	VI-VII	VII-VIII	C, VI, 62
k.811	Idem	Nāk Tā Tras	Idem	VI-VII	VII-VIII	C, VI, 63
k.816	Komṇoṅ Thoṃ	Prāsāt Robaṅ Romās	In Situ	VI	VIII	C, VI, 64
k.818	Siem Rāp	Prāsāt Khlāṅ	Idem	VI-VII	VII-VIII	C, VI, 65
k.877	Kandāl	Tûol Aṅ Rolāṅ Kèṅ	Idem	VI-VII	VII-VIII	C, VI, 66-8
k.884	Trā Vinh (Cochin-chine)	Trapāṅ Vêṅ (vill. de Nhi-Truòng)	Saigon : kp 30, 3	VI-VII	VII-VIII	C, VI, 69
k.903	Kandāl	Nāk Tā Svay Doṃbar	In Situ	VI-VII	VII-VIII	C, VI, 70
k.904	Siem Rāp	Bāray Occidental	Siem Rāp : 3.810.	635	713	C, IV, 54
k.910	Kandāl	Tûol Aṅ Sraḥ Thāt	Vāt Simphali	573	651	C, V, 39
k.922	Siem Rāp	Mébōn Occidental	In Situ	VI-VII	VII-VIII	C, VI, 71

k.926	Kracèḥ	Thma Krê	Idem	546	624	C, V, 20
k.927	Idem	Idem	Idem	630 (?)	708 (?)	C, V, 22
k.939	Tā Kèv	Aṅkor Borēi	Idem	VI	VII	C, V, 56
k.940	Kandāl	Nāk Tā Bāk Ka (vill. de Daṅ- kor)	Phnoṃ Péñ : 4.951; D1, 38	VI	VII	C, V, 73
k.956	Prei Vêṅ	Vāt Saṃroṅ de Phum Ciphoc	Idem : 6.444, 6.445 (D 3, 62, 63)	VI	VII	C, VII, 130
k.1010				VII	VIII	BE, 56, 71

រូបភាពសិលាចារឹកខ្លះៗនៃប្រទេសកម្ពុជា



សិលាចារឹក វត្តគំនូ អង្គរបូរី K.600 . 611A.D



Texte en translittération
(Aṅkor Borei,K.600,611 A.D.)
Face Nord

(1) traitriçottarapañcaçata çaka parigra[ha] trayodaçī ket māgha puṣya nakṣatra tulalagna ॰ poñ uy oy kñuṃ ai ta kpoñ kamratāṅ añ' ॰ va klapit I va kantāṅ srāṅ I va tloṅ I (2) va kcār I ku kantau I kon ku va alaṅ I ku ya leṅ I tmur 60 krapi 2 vave 10 toṅ teṃ 40 sre sanre 2 ai aṃpoṅ ॰ kñuṃ aṃnoy jaṃ añ ai ta vraḥ kamratāṅ añ mahāgaṇapati ॰ (3) va nñā I va kantāṅ I va knoc I va tmo I va daçamī I ku koñ vraḥ I ku juṅ poñ I ku mān ra añ I ku plas I tmur 20 kantai ta pos oy [ya]jamāna kpoñ I ta cuḥ tṅai vraḥ jon vṅe ṅnau danhuṃ I ci añ I tāñ I

Face Sud

(1) ..... āṅ vraḥ añ I dalā añ I
(2) ..... ku tpoñ I ku lacak I kon ku 3
(3)..... mratāṅ bhānu I kñuṃ ku tanmāru I va lavo I

Face Est

(1) kñuṃ vraḥ kamratāṅ añ [mani] çvara man mratāṅ antār oy saṃ paribhoga ai ta vraḥ kamratāṅ añ kamratāṅ teṃ kroṃ ॰ ramaṃ 7 ॰ caṃreṅ 11 tmīṅ viṇa kañjaṅ lāhv 4 ॰ (2) caṃ uk va paṃre kralā vraḥ 20-2 kñuṃ sre 40 - - tmur 100 krapi 20 sre ai kantok 10-7 sre ai caṃrai sanre 4 sre ai knar teṃ sanre 4 sre ai piṅ tvaṅ sanre 10 sre ai pradul sanre 2 ॰ (3) sre ai I laṃ añ sanre 2 daṃriṅ ai panla . aṅān I jmaḥ ge raṃ ॰ carumatī I priyasenā I aruṇamati I madanapriyā I samarasenā I va vasantamallikā I ॰ jmaḥ ge caṃreṅ ॰ tanvaṅgī I guṇadhāri I dayitavatī I sārāṅgī I (4) payodharī I ratimatī I stanottarī I rativindu I manovatī I pit añ I juṅ poñ I ॰ tmiṅ kanjaṅ sakhipriyā I madhurasenā I tmiṅ vīṇa gandhinī I tmiṅ lāhv vinayavatī I ॰ jmaḥ caṃ-uk va laṅsoṅ I va tpun I va ahvāṅ aṃve ley I (5) va sa-uy I va cke I va kañcan I va çivadāsa I va toy bhāgya I va kroṅ I va ṅā I va lābha I va la. u I va santos I va soc tarka I va ragāl I va prāsāda I va vrau I va ta-ūṃ I va krāñ I va kcī I va rapak I va cmā I ॰ jmaḥ ᵃnak sre ॰ (6) va tvaḥ I va tpaṅ I va aras I va caṃ-uk vraḥ I va tvin I va toh I va ty.I va. āṅ I va craṅ I va knāy I va cke I va tvāṅ I va kaṃpoñ I va jyeṣṭhahvarmma I va tvoc I va daçami I va adās I va phāñ I va panlas I ku cpoṅ I ku vnāk I (7) ku asaru I ku tacaṅ I ku tvāṅ I ku ta-āy I ku knur I ku mañjari I ku tyor I ku ya tey I ku ya pan I ku çaṃṅkha I ku ya ir I ku ya luṅ I ku raṅap I ku lahve I ku raṃnoc ta mān I ku klaṅ droṅ I ku tyuṅ I ku tvuc I (8) ku ravā I kon ku 2 ku kañheṅ I ku men kan I ku poñ vraḥ añ I ku kpoñ I ku laṅgāy I ku syāṃ po I ku taṃve ru I ku vaḥ kloñ I ku aras I ku asaru I ku vaḥ cī I ku putiḥ I ku mratāṅ I ku mratāṅ jīva I ku vrau srac I (9) ku aṃvai ru I ॰ kñuṃ vraḥ maṇīçvara aṃnoy ācāryya kandin I va nirākranda I va çivadāsa I va haradāsa I va kñuṃ vraḥ I va kiṅkara I va puṇyāçraya I va mitradatta I va dhara I kantai kloñ mratāṅ I loṅ añ I ku aras I (10) - - . l vṅā I tmur 10 ॰



Texte en translittération
(Kdey Aṅ K.54,VIIe.A.D.)

I (1) ācāryyavidyāvinayāhvayena
mayā punas saṃskṛtam atra bhaktyā
(2) samastadāyasthiram astu sarvva-
lokaikanāthasya çivasya liṅgaṃ
II (3) khapañcendriyage çāke rohiṇyāṃ çaçini sthite
(4) çivaliṅgan tadā tena devas saṃskriyate punaḥ
(5) sarvvasvaṃ bhāryyayā sārddhaṃ yajñadattasya bhojakaḥ
(6) çivadattād avāpyaitat çivaliṅgāya dattavān
(7) - - - - - - - - - - - s droṅ kñumm droṅ daṃmriṅ nirvvāṇa toṅ teṃ āy ta gui 100 (8) slā - - - - - sre tel poñ çivadatta oy āy ta añ ge phoṅ tel (9) añ oy āy ta vraḥ kamratāṅ añ çivaliṅga jmaḥ kñuṃ va purṇṇamī (10) I ku saṅhvāṅ añ dai ° va kandās ° va panhem ° va kaṃpoñ ° va uttara ° va cī vrau ° va saṃap ° (11) va kandos ° kantaiy mratāṅ çanaiçcara aṃnoy ta vraḥ kamratāṅ añ ku vñau ° kñuṃ vraḥ (12) daiy ku omadās ° kon ku va ta-el ° ku pallavī ° kñuṃ aṃnoy kurāk hvār ta vraḥ (13) va bhavadās ° aṃnoy va jleṅ ta vraḥ kamratāṅ añ va et ° aṃnoy somakīrtti ta (14) vraḥ ku dkok ° aṃnoy candrodaya āy ta vraḥ ku yajuṅ ° aṃnoy ācāryya samudra ta vraḥ (15) va trayodaçī ° aṃnoy poñ kantil āy ta vraḥ ku deviṅī ° va tvau ° spid dik tāṅ (16) prajñāsen āy ta añ kñuṃ va tkol ° damriṅ slā teṃ ta gui 100 toṅ teṃ 60 ° aṃ (17) noy bhavakumāra va dharmmasāra ° toṅ slā jhe antam nai vraḥ kamratāṅ añ daiy (18) kaṃluṅ gui rudrāçrama ° aṃnoy cī so āy ta vraḥ kamratāṅ añ va tanlap °
IV (19) nānātaruganākīrnnaṃ devāyatanam īdṛçam
kṛtaṃ nāmābhavat tena rudrāçrama iti smṛtam //



Texte en translittération
(khau Rang K. 505, 639.A.D.)

(1) iṣatrayodaçadine kṛṣṇe candrarasendriyaiḥ
(2) bhukte çakapater abde hastendur vṛṣabhodayaḥ
(3) kñuṃ aṃnoy sināhv pragat āy (4) ta vihār jmah ge vā sir kantai (5) ku yoṅ ₀ kon ku lāṅ si ₀ vā pār (6) kantai vā ku sol ₀ kon ku lāṅ tai ₀ (7) va raṅeh ku cih ₀ vā joṅ kantai (8) vā ku mās ° ku cū ° kon ku der tai ° lā (9) ṅ tai ° ku sralañ ° kon ku (10) lāṅ tai ° pau tai ° caṃdak vā thar ° vā (11) diṅ ° vā dharmmalābha ° daṃriṅ āy (12) tnon ° slā ta gui 100-5[1] ° toṅ teṃ 20 cmaṃ (13) gui vā men ° kantai vā ku laḥ ° kon ku lā (14) ṅ sī ° pau sī ° daṃriṅ āy ñiṅ vihā (15) r slā ta gui tneṃ 100-20-3 toṅ tneṃ 100-20 ° cmaṃ (16) gui vā kdok ° sarvvapiṇḍa savālavṛ (17) ddha kñuṃ phoṅ droṅ cmaṃ daṃriṅṅ 20-10-2 (18) glaṅ vihār klas saṃrit 4 thlās 2 (19) srageḥ 20 ° pallaṅka ° taṅtoṅ taṃpo (20) ṅ canlek uladdha jlī yau 7 kaṃvār (21) yau 7 kāpaṭa jlī yau 20-7 ° ksac (22) yau 10-2 kaṃvār yau 10 ° pnaṅ ° tridhā (23) vartma pi - - - - āy car ku sa (24) nre 1 kanlaḥ ti - - - - - - [kra] pi dneṃ (25) 5 ° poñ vu - - - - - - - - (26) kñuṃ aṃnoy sināhv añ ai ta vihā (27) [r] - - - - - - - kantai vā ku dhan ° kon (28) - - - - - - - - lāṅ sī ° pau tai ° thā (29) - - - - - - - - - - daṃriṅ 1 slā tneṃ - - - - - - - - (30) - - - - - - - - tneṃ gui 10 ° gui saṃ (31) - - - - - - - - ãy vihār ruṅ °

A

B

Texte en translittération
(Kūhā Luoṅ,K.44,678 A.D.)

A

I. (1) jayatīçaḥ pravṛtto pi nepsayā na jihāsayā
yasyecchācakraghaṭitaṃ viçaṃ bhramat sa naikadhā
II. (2) yena kandarppavapuṣā samudravasanā mahī
sahārimūrddhvamanibhiḥ vikramair adharīkṛtā
III. (3) jayinā nṛpatīndrena tena çrījayavarmmaṇā
ājñayā satyasandhyena sthitir evan nivaddhyate
IV. (4) kṣetragomahiṣārāma- bhṛtyādidhanasaṃpadaḥ
V. (5) çrīmad utpanneçvarasya haranti dravināni ye
te vasanty andhatāmisre yāvad arkkendutārakāḥ

(6) Saṇṇavtyuttarapañcaçata çaka parigraha ai mandira purandarapura pañcami ket kārtti (7) ka pūrvvāṣāḍhanakṣatra aṅgāradinavāra ājñā vraḥ kamratāṅ añ nī vraḥ kamra (8) tāṅ añ çrī utpanneçvara ta ai [c]n[ar] punya vraḥ kamratāṅ añ aṃnoy tāṅ (9) añ kloñ raṅ[k]o ₀ doṅ poñ varāhasena ai ta vraḥ kamratāṅ añ aṃvi (10) kāla vraḥ kamratāṅ añ çrī raudravarmma dāsa dāsī go mahiṣa kṣetrārā (11) mādi gi parimaṇḍala gi sre aṃvi dik hera loḥ vrai taṃpoṅṅ loḥ thalā (12) can cara loḥ travāṅ pās khmauhv loḥ cdiṅṅ lo[ḥ] stuk trass-nhora-i (13) poñ totil gui taṅ ājñā vraḥ kamratāṅ añ oy gui (14) sruk ple draṅ vnas nu poñ jon bhuti çreṣṭhāçrama

B

(1) loḥ travaṅ poñ viṣ[ṇu]kīrtti loḥ travaṅ pās tāṅ kanmeṅṅ loḥ gūha po aṃ (2) pakk vnaṃ vrai vnur caṃno[ṃ] tmur cdiṅ [a]nak ta paṅgaṃ nī dai gi tel ājñā vraḥ kamratā (3) ṅ añ prasiddha ai ta vraḥ kamratāṅ añ çrī utpanneçvara ta ai cnar smaṃ çresthā (4) çrama jmon bhūti gi voṃ saṃ dhanvipura ge ta hau saṃpol ta gi ge ta ckop (5) ucita saṃvatsara ta gi ge ta soṃ gi nā adhikāra ge ta hau [a]nak lvāṅ ta gi (6) ge ta hau vyavahāra dai ta gi ge ta dār dranap ghoṣnaṇā ta gi ge ta ca (7) p rddeḥ dok tmur krapi kñuṃ ta gi ge ta cracur vraneṅ chat duk snā (8) ṅ naṃ pitai kaṃluṅ aṅgaṇa vraḥ kamratāṅ añ paṃnos gi ta (9) tve pūjā vraḥ kamratāṅ añ poṃnos ta pos ta gi noḥ vnaṃ (10) vraḥ kamratān añ satva ta siṅ ta gi vojā ple [a]nak paribha (11) va āgama aṃvi ta gi noḥ sruk vraḥ kamratāṅ añ nu tve pūjā (12) vraḥ kamratāṅ añ ge ta soṃ gi ge ta dap gi ge ta pre roḥ (13) gi sot ge cer ājñā vraḥ kamratāṅ añ ge daṇḍa

Texte en translittération
(Tuol Aṅ Tnot K. 561)

I (1) jayaty açeṣalokānān nātha eko maheçvaraḥ
pratanoti sadāṣṭābhis tanubhir yyo khilañ jagat
II (2) çriraṇḍāparvvateçena kṛtaṃ çrījayavarmmaṇā
miçraṃ çrikhaṇḍaliṅgākhyaṃ triyomartuyute çake
III (3) çrīkhaṇḍaliṅge yad dattaṃ bhavacandrena yajvanā
putrapautrair aharttavyam anyaiç ca kulavāndhavaiḥ
IV (4) dravyaṃ çrīkhaṇḍaliṅgasya ye haranti narādhamāḥ
te vicinarakaṃ yāntu pitṛbhirvvāndhavais saha
V (5) saṃkhyyayā vi[ṅça]ti vrīher eko bhṛtyaḥ paṭadvayaṃ
saṃvatsaram ito dattaṃ çrīraṇḍāparvvateçvare
VI (6) utsveṣū[t]s[ave]ṣv eva taṇḍulañ ca yathocittam
nivandhanañca yas tyaktvā sa tāmisram ito gataḥ
(7) sattanivandha ple tdaiy āy ta vraḥ kamratāṅ añ çrī khaṇḍaliṅga man poñ bhava (8) candra oy sa ākra raṅko liḥ I vanli liḥ 3 si ple liḥ 2 satra paṃnos liḥ 2 satra (9) vñau liḥ I satra pitṛ liḥ I canlek ple vagṛṣā yogalla yau 4 aṃval yau I canlek pitṛ (10) aṃvlaḥ I satra kloñ mṛta raṅko liḥ I canlek aṃval vlaḥ satra kloñ trasauk (11) raṅko liḥ I canlek vlaḥ satra poñ jānavin ta vraḥ kamratāṅ añ çrī khaṇḍa (12) liṅga raṅko liḥ I canlek aṃval vlaḥ I satra poñ jānaprakāça raṅko liḥ I canlek (13) aṃval vlaḥ I satra kloñ tāñ raṅko liḥ I canlek aṃval vlaḥ I satra poñ vidyādharade (14 v) a raṅko liḥ I canlek aṃval vlaḥ I jivana saṃpol raṅko thloṅ 5 canlek yau I kñuṃ I aṃruṅ (15) sre vraḥ kamratāṅ añ çrī khaṇḍaliṅga smvi travaṅ [dha]rmma[k]īrtti loḥ travaṅ poñ bhāçānti loḥ (16) travaṅ poñ dharmmadeva loḥ tel ta travaṅ hvacc loḥ travaṅ poñ kdatt tarap gi jaṃnan (17) kurāk danle krohv lo[ḥ] travaṅ alāṅṅ loḥ travaṅ poñ devādhivāss loḥ travaṅ (18) mratāñ dharmme loḥ travaṅ poñ vinita loḥ travaṅ poñ siddhikīrtti loḥ travaṅ poñ (19) candrānan loḥ travaṅ ku kañcann loḥ travaṅ kloñ khe loḥ ta gi sre pradāna poñ kaṃvinn (20) ta āy vrai tlann gi aṃruṅ gi sre vraḥ kamratāṅ añ ç[r]ī khaṇḍaliṅga ge ta (21) sak gui ge ta kmi ta gui ge dau avīcinarakk dauṅ ge pitṛ ge dauṅ ge kull ge ta daṅ (22) ket sinn daṃmratāṅ añ tel kap pātra ge kule poñ (23) bhavacandra sanme ni dauṅ poññ ge oy kñau [ṃ] bhaiy I jmaḥ gui kñuṃ va kan I ku pu I ku (24) kan-as ku saṃap I vā kansoṃ I vā tnak I vā tkes I ku tvāy I ku vreṅ I vā sraṅe I vā (25) dha[r]mmadat I vā saṃvara I ku syer I ku chāñ I ku krohv I vā yacjadat I ku cakced vā dha (26) rmmacan I aṃraḥ vā teṅ I vā çveta kñuṃ ta man kloñ aṃmṛta oy ta vraḥ ku au I vā dharmmarakṣa I vā kan (27) saṃ I vā tyon I ku vrohv I vā caṃpeṅ I kñuṃ man poñ candrānna oy ta pitṛ ku kaṃput I kñuṃ man (28) kloñ trasok oy ta vraḥ vā suñiti I ku kandai kñuṃ ta man poñ jānaprakāça oy ta vraḥ ku karuṃ vā (29) koc vā saṃvar kñuṃ ta ma[n] poñ vinduçakti pradāna ta vraḥ kamratāṅ añ çrī khandaliṅga ku [a]nāda I (30) ku laṃnāṅ I vā subhava vā karon I ku jani-el I kñuṃ ta man mratāñ jānavin oy ta vraḥ kaṃmratāṅ añ (31) çrī khandaliṅga vā tmar I ku karoṃ kñuṃ ta man kloñ tāñ oy ta vraḥ ku tṅoh I kñuṃ aṃ (32) noy poñ bhavacandra ta vraḥ kaṃmratāṅ añ çrī khandaliṅga ku tpit I ku danso ku narek (33) vā dhanarakṣa I ku masi I ge tel poñ bhavacandra pre tve sre saṃpol pre caṃ ka-ol saṃpol pre caṃ posa (34) saṃpol ge diḥ paṃre ta vraḥ sin gui kañjrap ta man varta nā vraḥ kaṃmratāṅ añ çrī (35) kailāsovara tel poñ vidyākumāra psaṃ paribhoga ta vraḥ kaṃmrataṅ añ çrī khandali (36) ṅga aṃruṅ sre ta dai gui kañjrap tloṅ I kñuṃ I jaṃnon ākara ta vraḥ kaṃmratāṅ añ çrī khandaliṅga raṅko tloṅ I (37) caṅlek aṃval vlaḥ I pratisaṃvatsara ~ ku sa-ap - - - k gui kañjrap (38) kñuṃ man poñ jānaprakāça oy antyanti sot ta vraḥ [kaṃmratāṅ añ çr]ī khaṇḍaliṅga (39) ku chāñ I ku drahāy I kon ku ku krahvāñ I k - - - - - psaṃ nu gui (40) aṃ - - - - - - ge sanme ni camm raṅko ta - - - - - [aṃ] val vlaḥ I (41) ye - - - - satra ta roh - - - - - - ge tel (42) - - i



Texte en translittération

(Vat Tasar Moroy,K.124,803 A.D.)

I (1) jitam aparokṣajñānaṃ sarvvajñeyeṣu sarvvalokeṣu

(2) kartṛtvañ cākṣīṇaṃ yasyaitat tata - - - - -

(3) pañcaviṅçottarasaptaçata çakaparigraha gi nu [kanheṅ kamrateṅ] (4) añ ta cpoṅ kvan kanheṅ kamrateṅ añ çrījayendra '- rabhā [cau] (5) kanheṅ añ çrīnṛpendradevī cau dvot vraḥ kamrateṅ a (6) ñ çrindraloka jvan kñuṃ āy ta vraḥ kamrateṅ añ çrīmad āmr[ā] (7) taka kñuṃ vnok ᵃmuḥ dik sroṅ pamas gandha kuruṅ kṛtajñavana gi jmaḥ ku (8) rek kanyāt gi jmaḥ ᵃnak kloñ ta prabhū ta gi nuhv vibhava gi sa (9) rvvapiṇda gi kñuṃ nuhv tmonn 9 rūpya bhājana karap gi svok laṅgau cnaṅ (10) laṅgau ahvek laṅgau ⊙ vṛtti ta gi tmon canlek 20 yau - krapās tu (11) 4 jyeṅ 10 gmuṃ antvoṅ 3 mās 6 lṅo tloṅ I je I tvau tloṅ I je I (12) çunthi je 3 liḥ 9 kalmon jyeṅ 9 srū tloṅ 4 je 2 ⊙ ᵃnāc gi ca (13) nlek pan-eṅ yau 10 karap praṇāla yau I tnas - - yau I tnas tnal yau - (14) varṣā paṃnvos ta pjuḥ yau 3 paṃnvas ta taṃtaṃ carū yau 2 paṃnvas kloñ tā - (15) - tapra mān ta gi vṛttī yau I çunthī liḥ I vraḥ puṇya nai bhagavat kamrateṅ añ (16) utkṛṣṭa yau 5 krapās tul I ᵃmuḥ dik sroṅ yau I pamas gandha yau I vraḥ (17) puṇya kamrateṅ añ guru suvīra yau I gmuṃ antvoṅ 2 nu cāṃ carū nu sroṅ (18) pañcotsava gmuṃ antvoṅ I mās 6 nu duñ pareṅ canlek yau 2 duñ ṅra (19) ṅor krapās tul I duñ pareṅ tul 2 jyeṅ 10 duñ caruk çunthī je - (20) liḥ 6 duñ slā nu carukk lṅo cāṃ pañjut tvau cāṃ carū kalmon caṃ sandhyā (21) srū satra paṃnvas ta pjuḥ 20-4 paṃnvas ta taṃtāṃ carū tloṅ 10-8

II (22) tasmai çivāya gurave jyeṣṭhāryyākhyā namaskṛtvā

(23) bhaktyanumānārtham idaṃ sarvvaṃ prādād iyaṃ rājñī //

III (24) ebhiḥ puṇyaphalair devī nava - t[e]ha bhaktaye

(25) çambhave ta phalatyāgād aiçaṃ padam avāpnuyāt ⊙



K. 24 A. Ankor Borei. , V – VI C , C II

Texte en translittération (Aṅkor Borey K. 24)

Face A

(1)-------dit poñ vrau ₀ va knoc ₀ va tmās ₀ va kl ---------- (2) ---------- hv ₀ ti kantaiy ku ñañ ₀ pau tai ₀ ku ya huṅ ₀ ku ya ---------- (3) ---------- c daṅ ₀ va aṇḍaṅ ₀ va señ ten . va ta au ₀ va ta uy ₀ ---------- (4) --------- va - lku - ₀ va ta - - ₀ va tpeṅ ₀ va tvaiy ₀ va lahvāy ₀ va vleṅ ₀ va - - ṅ ---------- (5) ---------- hv ₀ va - kuñ ₀ va latuḥ ₀ va tānmar ₀ va pāy añ ₀ va kāhv seṅ ₀ va jeṅ ₀ va ta ol ₀ va --------- (6) --------- va laṇḍan ₀ va lahvā ₀ va cār ₀ va tahvan ₀ va slā ₀ va tralā pju ₀ va t a uḥ ₀ va vrai ₀ va tkuñ ₀ va kantāṅ ₀ va ---------- (7) ---------- vaṅ ₀ va dak ₀ [va] ta oṅ ₀ va gulut ₀ va clohv ₀ va - - ₀ va tvaṅ ₀ va ta oḥ ₀ va k - ṃ ₀ va ta duy ₀ va ta ca - ₀ va - y --------- (8) --------- va tgor ₀ va tvaḥ ₀ va tkaṅ ₀ va kliṅ ₀ va grec ₀ va - ñcaṅ ₀ va tma - ₀ va gñaḥ va kuñjahv ₀ va tyas ₀ va ustai ₀ va kañcaṅ ₀ va ka --------- (9) --------- ku priṅ ₀ ku ᵃme ca tuṅ ₀ ku ktaṅ ₀ ku bekan ₀ku yavai ₀ku - cat ₀ ku p-heṃ ₀ ku ya laḥ ₀ ku stūr ₀ kur --------- (10) --------- ku ya se - ₀ ku ya - - - ₀ ku ya ṅau ₀ ku [ya] pāc ₀ ku ya men ₀ pau sī ₀ ku ya - ₀ pau tai ₀ ku ya sat ₀ pau --------- (11) --------- pau tai ₀ ku ta āy ₀ pau sī ₀ ku ya mās ₀ ku karttavaṅ ₀ ku tye ₀ ku kantakoy ₀ ku ta āy ₀ ku ya caṅ ₀ ku ya mun ₀ ---------- (12) ---------- ku ya vaṅ ₀ kume tyuk ₀ ku kañcu ₀ ₀ ku prahvel ₀ ku ya vomṃ ₀ ku ya kān ₀ ku ya roñ ₀ ku ya - ñ ₀ lāṅ si ₀ - - ku ya ---------- (13) ---------- ce - ₀ ku ya lahv ₀ ku kantavaṅ ₀ ku ya - - ₀ ku sarac ₀ ku ya māl ₀ ku me vrai ₀ ku ta - - ₀ ku ya kā - ₀ ku ya --------- ------ (14) ---------- vi nāsa pa gū ₀ ku hvaḥ ₀ ku me ke - ₀ ku met ₀ ku - tkaṅ ₀ ku kañjahv ₀ ku cāk ₀ ku mās ₀ ku liñ ₀ ku --------- ₀ (15) --------- ku ya - ₀ ku ya - ñ ₀ ku mana ₀ ku tgul ₀ ku - . ī ₀ ku - ₀ ku suc ₀ ku tmañ ₀ ya - ₀ yal. - ₀ ya ñ - hv ₀ ya roṅ ₀ ---------(16) --------- seṅ pau ---------- santan ta - l ₀ ya caṅ ₀ ta vhey ₀ - - - ku men ₀ po - - -

Face B

